**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

លេខ: ០៧១/២៦ ឃ៨.

# របាយការណ៍
# ស្តីពី
# ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
# ប្រចាំខែមីនា និងទិសដៅខែមេសា ឆ្នាំ២០២៦

## I. ស្ថានភាពទូទៅ

ពិភពលោក កំពុងនៅតែប្រឈមដោះស្រាយវិបត្តិសេដ្ឋកិច្ចជាសកល ផលប៉ះពាល់នៃគ្រោះធម្មជាតិ ដែលកើតឡើងដោយបម្រែបម្រួលអាកាសធាតុ និងជម្លោះប្រដាប់អាវុធដ៏រ៉ាំរ៉ៃ និងសង្គ្រាមបង្ហូរឈាម វិបត្តិនយោបាយបានកើតឡើង ជាបន្តបន្ទាប់ និងរាលដាលពីតំបន់មួយទៅតំបន់មួយ ចរន្តគាំពារនិយម ភាពក្រីក្រចេះតែមានចំនួនកើនឡើងជាបន្តបន្ទាប់ ជាបុព្វហេតុជំរុញឱ្យមនុស្សរាប់លាននាក់ បង្ខំចិត្តចាកចេញពីផ្ទះសម្បែង ឬទីតាំងដែលខ្លួនរស់នៅ ហើយធ្វើទេសន្តរប្រវេសន៍ដោយគ្មានការត្រៀមទុក ដែលក្លាយជាចលនាវំហូរពលករដែលគ្មានឯកសារ ខ្វះការគ្រប់គ្រង និងប្រឈមយ៉ាងខ្លាំងទៅនឹងកង្វះសុវត្ថិភាព អំពើរំលោភបំពាន ការកេងប្រវ័ញ្ចជាច្រើនរូបភាព និងអំពើជួញដូរមនុស្ស។ អំពើជួញដូរមនុស្ស ការរំលោភសិទ្ធមនុស្ស រំលោភសណ្តាប់ធ្នាប់ពិភពលោក ច្បាប់អន្តរជាតិ ជារឿងស្មុគស្មាញ និងជាបញ្ហាដ៏ធំមួយនៃសង្គមមនុស្សជាតិក្នុងពិភពលោក ដែលកើតឡើងដោយសារកត្តារួមផ្សំជាច្រើន ។

ប្រព័ន្ធផ្សព្វផ្សាយដ៏សម្បូរបែប និងការផ្សព្វផ្សាយ នៃបណ្តាញសារព័ត៌មាននានាមួយចំនួន បានលាយឡំទាំងព័ត៌មានពិត និងមិនពិត រួមទាំងនិន្នាការ និងភូមិសាស្ត្រនយោបាយផងនោះ បានវាយតម្លៃអំពីស្ថានភាពនៃបទល្មើសជួញដូរមនុស្សនៅកម្ពុជា។ ទន្ទឹមនឹងនោះការចោទប្រកាន់ពីបណ្តាប្រទេសមួយចំនួន ដែលមានពលរដ្ឋមកប្រព្រឹត្តបទល្មើស ឬមករងគ្រោះនៅកម្ពុជា ក៏បានធ្វើឱ្យមានការភ័ន្តច្រឡំ និងវាយតម្លៃជាអវិជ្ជមានលើស្ថានភាពសន្តិសុខនៅកម្ពុជា ដែលផ្ទុយពីឆន្ទះរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងស្ថានភាពពិតជាក់ស្តែងនៅកម្ពុជា ។

ការផ្សព្វផ្សាយអំពីឱកាសការងារ និងការជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេស ទាំងតាមប្រព័ន្ធផ្លូវការ ទាំងតាមបណ្តាញសង្គម និងមួយចំនួនធំជាការអូសទាញរបស់បណ្តាញជនល្មើស បានក្លាយជាកត្តាជំរុញ និងទាក់ទាញប្រជាពលរដ្ឋក្នុងតំបន់ និងពីបណ្តាប្រទេសនានា ក្នុងពិភពលោក ក៏ដូចជាប្រជាជនកម្ពុជា ដែលពេញវ័យការងារ ឱ្យចាប់អារម្មណ៍ និងសម្រេចចិត្តយ៉ាងឆាប់រហ័ស និងផុលផុសក្នុងការធ្វើចំណាកស្រុក ឬធ្វើទេសន្តរប្រវេសន៍ទៅរកការងារ ដែលមានបៀវត្សរ៍ខ្ពស់ ជាពិសេសពាក់ព័ន្ធនឹងសកម្មភាពឆបោក។

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាសេនាធិការ បានចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scam) ជាអាទិភាពមួយក្នុងចំណោមអាទិភាពដទៃទៀត រួមទាំងផលប៉ះពាល់នៃគ្រឿងញៀន គ្រឿងស្រវឹង គ្រោះថ្នាក់ចរាចរណ៍ និងបានដាក់ចេញនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដោយខិតខំជំរុញសកម្មភាពឥតឈប់ឈរ ដើម្បីការពារសុវត្ថិភាព និងសន្តិសុខមនុស្ស ក៏ដូចជាសន្តិសុខជាតិទាំងមូល ដើម្បីទ្រទ្រង់ដំណើរការអភិវឌ្ឍន៍គ្រប់វិស័យ នៃសង្គមជាតិ។

នៅក្នុងខែមីនានេះ គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងរាជធានី ខេត្ត នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់កម្រិត និងដោយមានការចូលរួមគាំទ្រ សហការពីអង្គការដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ បានធ្វើសកម្មភាពប្រតិបត្តិការយ៉ាងសកម្ម ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីឆ្លើយតបនឹងស្ថានភាពប្រែប្រួល ពិបាកប៉ាន់ស្មាននៃបទល្មើសជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀតដែលបង្កឡើងដោយឧក្រិដ្ឋជន រួមទាំងបទល្មើសឆបោកតាមប្រព័ន្ធអនឡាញផងដែរ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការបង្ការ ទប់ស្កាត់

#### ក.១. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយផ្ទាល់

ក្រុមការងារបង្ការ ទប់ស្កាត់ នៃ គ,ជ,ប,ជ ដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា ដែលមានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយតាមរយៈ យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិតទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" វេទិកាសាធារណៈ និងការបញ្ជ្រាបការផ្សព្វផ្សាយតាមកម្មវិធីផ្សេងៗ សរុបចំនួន ២២,៨៨៧លើក មានអ្នកចូលរួមសរុបចំនួន ១,០៥២,៧៧៦នាក់ ក្នុងនោះស្ត្រី ៥៨៩,៩៧១នាក់ (ប្រៀបធៀបនឹងខែកុម្ភៈ មានចំនួន ១,១២០,១៦៣នាក់) ថយចុះ ៦៧,៣៨៧នាក់ ស្មើនឹង ៦% ដូចមានក្នុងតារាងខាងក្រោម៖

*តារាងទិន្នន័យសរុបការផ្សព្វផ្សាយដោយផ្ទាល់*

| ល.រ | សកម្មភាពផ្សព្វផ្សាយ | ចំនួនដង/លើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត | ០៤ | ៥២៤ | ២៦២ |
| ២ | ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០២៥ -ថ្នាក់ក្រោមជាតិ (១៤ខេត្ត) | ១៥ | ៦,១៨៤ | ២,០៨៨ |
| ៣ | ច្បាប់ វេទិកាសាធារណៈ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព | ២២,៧៧៦ | ១,០៣២,១៦២ | ៥៧៩,៦១៨ |
| ៤ | កម្មវិធីផ្សេងៗ | ៩២ | ១៣,៩០៦ | ៨,០០៣ |
| | សរុប | ២២,៨៨៧ | ១,០៥២,៧៧៦ | ៥៨៩,៩៧១ |

*(សម្គាល់៖ ចំនួននេះមិនគិតអ្នកដែលបានទទួលព័ត៌មានតាមរយៈការចែកខិត្តប័ណ្ណ បណ្តាញសង្គម ឬការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិកត្រូនិកផ្សេងទៀតឡើយ)*

❖ **យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត**

**ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** សហការជាមួយ គ្រឹះស្ថានសិក្សាឯកជននៅរាជធានីភ្នំពេញ(សាលា AIS ច្បារអំពៅ និង AIS ចោមចៅ) និងគាំទ្របច្ចេកទេសដោយក្រុមហ៊ុន Smart Axiata និង អង្គការ APLE បានប្រារព្ធកម្មវិធី យុទ្ធនាការគាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត ឆ្នាំ២០២៦ ក្រោមប្រធានបទ «ប្រើប្រាស់ AI ប្រកបដោយសុវត្ថិភាព ក្រមសីលធម៌ និងការទទួលខុសត្រូវ» ចំនួន ០៤លើក ដោយមានការអញ្ជើញចូលរួមជាអធិបតី លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ.ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ ឯកឧត្តមអគ្គលេខាធិការរង លោកគ្រូ អ្នកគ្រូ និងសិស្ស សរុបប្រមាណ ៥២៤នាក់ ស្រី ២៦២នាក់។

❖ **ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥**

គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ បានរៀបចំពិធីអបអរសាទរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ក្រោមប្រធានបទ "រួមគ្នាដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស និងអំពើឆបោកតាមអនឡាញ" សរុបចំនួន ១៤លើក អ្នកចូលរួមចំនួន ៦,១៨៤នាក់ ស្រី ២,០៨៨នាក់ ក្នុងនោះមានខេត្ត៖ សៀមរាប ១,០០០នាក់(ស្រី៤០៩), បន្ទាយមានជ័យ ៧០០នាក់(ស្រី៣០០), កំពង់ចាម ៦០៦នាក់(ស្រី៣៨៨), កំពង់ឆ្នាំង ៥២០នាក់, ឧត្តរមានជ័យ ៤០០នាក់, តាកែវ ១៨៤នាក់(ស្រី២៣), ស្ទឹងត្រែង ៣០៤នាក់, កែប ៣១២នាក់ មណ្ឌលគិរី ៣២៩នាក់(ស្រី១៤៣), ត្បូងឃ្មុំ ៣៧៨នាក់(ស្រី១៨៤), ក្រចេះ ២៤៥នាក់(ស្រី១១៧), ព្រះវិហារ២លើក ២៧៥នាក់(ស្រី៧៥), ស្វាយរៀង ៤៥០នាក់(ស្រី១៩៣), ព្រះសីហនុ ៤៨១នាក់(ស្រី ២៥៦)។

## ❖ ការផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ និងភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព

គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) មន្ទីរ អង្គភាព និងអង្គការដៃគូពាក់ព័ន្ធ បានធ្វើការផ្សព្វផ្សាយផ្ទាល់ដល់ប្រជាពលរដ្ឋរួមគ្នា និងដោយឡែកពីគ្នា តាមរយៈការផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ វេទិកាសាធារណៈ និងតាមការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" សរុបចំនួន ២២,៧៧៦លើក មានអ្នកចូលរួមសរុបចំនួន ១,០៣២,១៦២នាក់ ក្នុងនោះស្ត្រីចំនួន ៥៧៩,៦១៨នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| តារាងទិន្នន័យវេទិកាសាធារណៈ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | | | | | | |
|---|---|---|---|---|---|---|---|
| ល.រ | ក្រសួង ស្ថាប័ន រាជធានី ខេត្ត | ផ្សព្វផ្សាយ/ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | | វេទិកាសាធារណៈ | | |
| | | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្ត្រី | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្ត្រី |
| ថ្នាក់ជាតិ | | | | | | | |
| ១ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | ១២ | ១,៤១៥ | ៧២៦ | | | |
| រាជធានី ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | ៨៣ | ១៩,៦០៣ | ១០,១២៣ | ១៧ | ៩៩៤ | ៥៧៧ |
| ២ | ខេត្តកណ្តាល | ៩៣៣ | ៤២,៧៣១ | ៤១,១០០ | ១,៥៨១ | ៥៨,៨០៤ | ២៧,៧៧៨ |
| ៣ | ខេត្តបាត់ដំបង | ៨៨២ | ៥២,៣៧៦ | ២៩,៨៣៧ | ៦៥៥ | ២២,៤៥៤ | ១២,៨៩៨ |
| ៤ | ខេត្តពោធិ៍សាត់ | ៦៤០ | ៤៩,១២៤ | ២០,៥៨០ | ៣៦៩ | ១៥,៩១៥ | ៨,១៤១ |
| ៥ | ខេត្តសៀមរាប | ១,១៩៦ | ៨៨,៧៨០ | ៥៤,១០២ | ៩៩៨ | ៣៨,៥៩៤ | ២៣,៩៧៨ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៧១៩ | ២៨,៨៣៤ | ១៥,២៦២ | ៥៤០ | ១៤,៩៣០ | ៧,៩៨៤ |
| ៧ | ខេត្តកំពង់ចាម | ២,៤៨០ | ១៣០,៥៦៨ | ៦៩,៧៧២ | ១,០៣៨ | ៤៣,៦៩៧ | ២៤,៤៤៥ |
| ៨ | ខេត្តព្រះសីហនុ | ១៦៥ | ៤,៩០២ | ២,២៥៧ | ៥៩ | ១,៧២៤ | ៧៩៤ |
| ៩ | ខេត្តព្រះវិហារ | ០៩ | ៥២៧ | ៣២៥ | | | |
| ១០ | ខេត្តស្វាយរៀង | ៥៥៩ | ២៤,៨៤១ | ១៣,៨៨៣ | ៤៤៩ | ១៦,៩២១ | ៩,៣១៨ |
| ១១ | ខេត្តប៉ៃលិន | | | | | | |
| ១២ | ខេត្តកោះកុង | ១,៦០០ | ៣០,៤១៩ | ១៤,៦៣៨ | ៤០១ | ៦,៦២១ | ៣,០១២ |
| ១៣ | ខេត្តកំពត | | | | | | |
| ១៤ | ខេត្តកំពង់ធំ | ៤៩២ | ៣០,៩៤៤ | ១៩,៧៨៩ | ៣២៧ | ១០,០៦០ | ៦,០៥៤ |
| ១៥ | ខេត្តតាកែវ | ៩២ | ៥,២៤៥ | ២,២២២ | ៥៥៨ | ២២,៤២៥ | ១៧,៦០១ |
| ១៦ | ខេត្តក្រចេះ | ៦៧ | ២,៨៦៥ | ១,៥៨៧ | | | |
| ១៧ | ខេត្តកែប | ៧៣ | ១២,៧១២ | ៥,៤៣៧ | ១៣៨ | ៦,១១៧ | ២,៩៩៨ |
| ១៨ | ខេត្តកំពង់ស្ពឺ | ៦៩៧ | ៤១,៣៥៤ | ២១,២២៣ | ១៥១ | ៧,២១៨ | ៣,៣៣៩ |
| ១៩ | ខេត្តស្ទឹងត្រែង | ២០០ | ១៥,៤៣៨ | ៨,២២៣ | ១៦១ | ៥,៧៤៩ | ៣,១៥៤ |
| ២០ | ខេត្តរតនគិរី | ៦៣៥ | ៣១,៤៤០ | ១៥,៨៧៩ | ៣៤៦ | ១៧,០៣៥ | ៨,៩០០ |
| ២១ | ខេត្តព្រៃវែង | ៩២៧ | ៥៩,៤២៤ | ៣២,៩៥៥ | ៦២០ | ១៨,៨៣៥ | ១០,១១៩ |
| ២២ | ខេត្តត្បូងឃ្មុំ | ០២ | ៦៦០ | ៤៨០ | ១៦៣ | ៥,២៨៨ | ២,៤២២ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ៩៥៤ | ១៥,៤១៤ | ៩,៤៧៩ | ២៦៦ | ៦,៧៣៦ | ៤,២៨៤ |
| ២៤ | ខេត្តឧត្តរមានជ័យ | ៣២៦ | ១៦,៣៤១ | ៨,៨៤៩ | ១៦ | ១,១៤១ | ៦៥២ |
| ២៥ | ខេត្តមណ្ឌលគិរី | ១៦០ | ៤,៦១៨ | ២,២៩៩ | ២០ | ៣២៩ | ១៤៣ |
| សរុប | | ១៣,៨៩១ | ៧០៩,១៦០ | ៤០០,៣០១ | ៨,៨៧៣ | ៣២១,៥៨៧ | ១៧៨,៥៩១ |
| សរុបរួម | | ២២,៧៧៦ លើក | | ១,០៣២,១៦២ នាក់ | | ៥៧៩,៦១៨ នាក់ | |

## ❖ ការបញ្ជ្រាបការយល់ដឹងតាមរយៈកម្មវិធីផ្សេងៗ

| ល.រ | រាជធានី ខេត្ត អង្គការ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ខេត្តបាត់ដំបង | ៣៣ | ៣,២៥៩ | ១,៤៤០ |

| | | | | |
|---|---|---|---|---|
| ២ | ខេត្តសៀមរាប | ១៦ | ៤៣៧ | ៣១៩ |
| ៣ | ខេត្តកំពង់ឆ្នាំង | ០៧ | ៤៧២ | ២៧២ |
| ៤ | ខេត្តកំពង់ចាម | ១៥ | ២,៥៩០ | ១,៨៨៥ |
| ៥ | ខេត្តឧត្តរមានជ័យ | ០១ | ១១ | ០៦ |
| ៦ | ខេត្តបន្ទាយមានជ័យ | ០៩ | ៥៧៤ | ២៥៧ |
| ៧ | ខេត្តកំពង់ស្ពឺ | ១៣ | ៥៦០ | ២៨៣ |
| ៨ | ខេត្តកែប | ០១ | ៣៣០ | ២០៧ |
| ៩ | អង្គការម្លប់តាប៉ាង(ព្រះសីហនុ) | ០៣ | ៥៣៣ | ៥០ |
| ១០ | អង្គការជលជារជីវិត(ព្រះសីហនុ) | ០២ | ២៤១ | |
| សរុប | | ៩២ លើក | ១៣,៩០៦ នាក់ | ៨,០០៣ នាក់ |

## ក.២. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយមិនផ្ទាល់

❖ **ការផលិត និងចែកផ្សាយ សម្ភារផ្តល់ព័ត៌មាននិងអប់រំ** IEC ( Information Education Communication Materials)

▪ **រាជធានីភ្នំពេញ៖** រដ្ឋបាលក្រុងភ្នំពេញបានផ្សព្វផ្សាយតាមរយៈ DVD Video ផ្តល់ការអប់រំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់អ្នកទេសចរសរុបចំនួន ៧៤៩,០០០នាក់ ទេសចរជាតិ **៧២៧,០០០**នាក់ ទេសចរបរទេស ២២,០០០នាក់ (តាមផ្លូវថ្មើជើងចតុមុខ)។

▪ **ខេត្តសៀមរាប**

- លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តសៀមរាប បានសហការជាមួយ គណៈកម្មាធិការជាតិ គ.ជ.ប.ជ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត អង្គការមូលនិធិអេ២១ និងផលិតកម្ម LifeMelody បានផលិតរឿងអប់រំខ្លីក្រោមចំណងជើង "ផ្កាស្រុក" ដើម្បីទប់ស្កាត់ការធ្វើទេសន្តរប្រវេសន៍មិនប្រក្រតី ឬមិនរៀបរយ និងដើម្បីលើកកម្ពស់ឱកាសទទួលបានការងារក្នុងប្រទេស និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ របស់ពលករដែលបានវិលត្រឡប់មកពីធ្វើការក្រៅប្រទេស ដោយមានការចូលរួមសម្តែងពីយុវជនចំនួន ២១នាក់ មកពីវិទ្យាល័យ១០មករា ១៩៧៩ វិទ្យាល័យសម្តេចឪ និងវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសៀមរាប

- មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត បានបោះពុម្ព និងចងបដាចំនួន **៣ផ្ទាំង** ដែលមានខ្លឹមសារទប់ស្កាត់អំពើជួញដូរមនុស្ស សម្រាប់ផ្សព្វផ្សាយនៅក្នុងទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៨ ឆ្នាំ២០២៦ ក្រោមប្រធានបទ "យុវជនដើម្បីវប្បធម៌"

- ក្រុមការងារក្រុងសៀមរាប និងស្រុកពួក ចែកខិត្តប័ណ្ណផ្សព្វផ្សាយពីគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ការធ្វើចំណាកស្រុក ការស្វែងរកជំនួយ និងលេខទូរស័ព្ទអាជ្ញាធរមានសមត្ថកិច្ច ជូនប្រជាពលរដ្ឋ បានចំនួន ៩,៣២៥សន្លឹក

- វិទ្យាស្ថានជាតិពហុបច្ចេកទេសអគរ ចែកខិត្តប័ណ្ណផ្សព្វផ្សាយ ស្តីពីព័ត៌មានសិក្សាជំនាញបច្ចេកទេស និងវិជ្ជាជីវៈ បានចំនួន ៩០០សន្លឹក

- មជ្ឈមណ្ឌលការងារខេត្ត ផ្សព្វផ្សាយនិងចែកខិត្តប័ណ្ណ/កម្មវិធី អំពីព័ត៌មានទីផ្សារការងារ បានចំនួន ២,០០០ខិត្តប័ណ្ណ/កម្មវិធី។

▪ **ខេត្តកំពង់ចាម៖** ក្រុមការងារទេសន្តរប្រវេសន៍ នៃមន្ទីរការងារ បានសហការជាមួយអង្គការភ្នំស្រីដើម្បីអភិវឌ្ឍន៍ និងវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម ចុះចែកខិត្តប័ណ្ណផ្សព្វផ្សាយ ស្តីពីការស្វែងរកការងារធ្វើក្នុងស្រុកចំនួន ៣០០សន្លឹក នៅស្រុកស្ទឹងត្រង់ និងស្រុកព្រៃឈរ។

▪ **ខេត្តឧត្តរមានជ័យ៖** បានចុះអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ សិស្សានុសិស្ស និងចែកខិត្តប័ណ្ណផ្សព្វផ្សាយ ចំនួន ១,១៨០សន្លឹក។

▪ **ខេត្តបន្ទាយមានជ័យ៖** អង្គការសាម៉ារីតាន់ភីសសង្គ្រោះអន្តរជាតិ បានចែកខិត្តប័ណ្ណអំពី រួមគ្នាទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករ និងសហគមន៍ សរុបចំនួន ៤៣៣នាក់ ស្រី ១៥១នាក់។

❖ **ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

▪ រាជធានីភ្នំពេញ៖ មន្ទីរព័ត៌មាន បានធ្វើការផ្សព្វផ្សាយសារអប់រំខ្លីៗ ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស តាមប្រព័ន្ធផ្សព្វផ្សាយមានដូចជា ហ្វេសប៊ុកផេក ឆេលណែលតេឡេក្រាម ទីកតុក ទូរទស្សន៍អនឡាញ ដូនពេញ ផ្សាយបន្តផ្ទាល់ពីទទក បានចំនួន ៣,៥៧៩លើក។

▪ ខេត្តសៀមរាប៖ មន្ទីរព័ត៌មាន បានផលិតកម្មវិធី២សំខាន់ៗ ធ្វើការផ្សាយផ្ទាល់តាមរយៈវិទ្យុជាតិនគរភ្នំ និងទូរទស្សន៍ជាតិខេត្ត ទូរទស្សន៍ខ្សែកាបអង្គរ តាមប្រព័ន្ធអនឡាញ ស្តីពីការទប់ស្កាត់អំពើហិង្សានៅក្នុងគ្រួសារ ការធ្វើចំណាកស្រុកខុសច្បាប់ និងការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ បានចំនួន ៨៨លើក ក្នុងនោះផ្សាយផ្ទាល់ ២៤លើក ចាក់ផ្សាយឡើងវិញ ៦៤លើក។

▪ ខេត្តកំពង់ចាម៖ មន្ទីរព័ត៌មាន បានផ្សព្វផ្សាយតាមរយៈវិទ្យុក្នុងកម្មវិធីសន្ទនាមតិ ចំនួន ៣លើក ក្រោមប្រធានបទ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

▪ ខេត្តព្រៃវែង៖ មន្ទីរព័ត៌មាន បានផ្សព្វផ្សាយសារអប់រំនៃការជួញដូរមនុស្ស តាមវិទ្យុបាពយណ៍អណ្តែត បានចំនួន ៥០ដង ដោយក្នុង១ថ្ងៃ ៥លើក។

▪ ខេត្តកោះកុង៖ មន្ទីរព័ត៌មាន បានផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ តាមវិទ្យុ បានចំនួន ១៨០លើក។

▪ ខេត្តតាកែវ៖ មន្ទីរព័ត៌មាន បានផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ តាមវិទ្យុ បានចំនួន ៦៥ដង។

▪ ខេត្តត្បូងឃ្មុំ៖ មន្ទីរព័ត៌មាន បានចាក់ស្ប៉តអប់រំតាមរយៈវិទ្យុជាតិ ស្តីពីការជួញដូរក្រៅប្រទេស បានចំនួន ១២៥ដង និងខ្លឹមសាររឿងពាក់ព័ន្ធការជួញដូរផ្លូវភេទចំនួន ៣២ដង។

▪ ខេត្តប៉ៃលិន៖ មន្ទីរព័ត៌មាន ផ្សព្វផ្សាយតាមរយៈវិទ្យុ និងទូរទស្សន៍ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងមួយថ្ងៃ៨លើក ស្មើនឹង ៤៩៦លើក ក្នុងមួយខែ។

▪ ខេត្តកំពង់ស្ពឺ៖ មន្ទីរព័ត៌មាន បានផ្សព្វផ្សាយតាមវិទ្យុជាតិគិរីរម្យ អំពីស្ប៉តការប្រយុទ្ធប្រឆាំងអំពើជួញដូរស្ត្រី និងកុមារ រៀងរាល់ថ្ងៃក្នុងមួយថ្ងៃផ្សាយ ២០លើក សរុបចំនួន ៦០០លើក។

❖ **ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ និងនៅតាមស្ថានីយវិទ្យុ ទូរទស្សន៍**

▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញផ្តល់កិច្ចសម្ភាសន៍ និងផ្តល់អនុសាសន៍ដល់ អង្គការ IOM ក្នុងការសិក្សាវាយតម្លៃ ប្រសិទ្ធភាពការអនុវត្តគម្រោង «ការគាំទ្រគោលនយោបាយ និងកម្មវិធីផ្អែកលើភស្តុតាងក្នុងបរិបទ នៃការចល័តឆ្លងកាត់ព្រំដែន ប្រទេសកម្ពុជា និងវៀតណាម»។

▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៊ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញផ្តល់បទកិច្ចសម្ភាសន៍ ជូន ស្ថានីយទូរទស្សន៍បាយ័ន ស្តីពីសារអប់រំផ្សព្វផ្សាយ ដើម្បីបង្កើនការយល់ដឹងបន្ថែមពីល្បិចកលនៃការឆបោក និងការកេងប្រវ័ញ្ចលើស្ត្រី និងក្មេងស្រី ពាក់ព័ន្ធអំពើជួញដូរមនុស្ស ក្នុងឱកាសទិវានារីអន្តរជាតិខួបលើកទី១១៥ នៅបន្ទប់ប្រជុំ គ.ជ.ប.ជ។

▪ ខេត្តសៀមរាប

- នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិនក្នុងស្ថានីយ៍វិទ្យុ ១លើក ស្តីពីការរួមគ្នាទប់ស្កាត់អំពើជួញដូរមនុស្សក្នុងសម័យបច្ចេកវិទ្យា

- នាយកការិយាល័យកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល បានចូលរួមជាវាគ្មិន ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព

- តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត និងប្រធានមជ្ឈមណ្ឌលការងារខេត្ត បានចូលរួមជាវាគ្មិន ស្តីពីការលើកកម្ពស់មុខរបរ និងការផ្តល់ឱកាសការងារដល់ពលករចំណាកស្រុកមកពីប្រទេសថៃ។

▪ **ខេត្តព្រៃវែង៖** តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមជាវាគ្មិនធ្វើបទបង្ហាញក្នុងវគ្គបណ្តុះបណ្តាលស្តីពី "យន្តការទទួលពាក្យបណ្តឹងសម្រាប់ពលករទេសន្តរប្រវេសន៍" ដែលរៀបចំដោយមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ខេត្តព្រៃវែង មានអ្នកចូលរួមសរុប ៣៧នាក់ ស្រី២៥នាក់។

▪ **ខេត្តកំពង់ចាម៖** តំណាងស្នងការនគរបាលខេត្ត បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ របស់វិទ្យុជាតិខេត្ត ២លើក ប្រធានបទ ស្តីពីការដាស់តឿនយុវជន កុំឱ្យភ្លើតភ្លើនខុសប្រព្រៃណី នៅថ្ងៃបុណ្យនៃក្តីស្រលាញ់ និងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី តាមប្រព័ន្ធបច្ចេកវិទ្យា។

### ក.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

❖ ការធ្វើអធិការកិច្ចការងារ

▪ **ខេត្តសៀមរាប៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានធ្វើការត្រួតពិនិត្យ និងគ្រប់គ្រងកម្មករខ្មែរ និងជនបរទេស និងការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ

- ធ្វើបច្ចុប្បន្នភាព សហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជីបញ្ចូលក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធសរុបចំនួន ៣,៣៧២ សហគ្រាស មានកម្មករនិយោជិត ចំនួន ៣៨,៥១៦នាក់ ស្រី ១៨,០៩០នាក់
- បានផ្តល់សៀវភៅការងារទិដ្ឋាការចេញ-ចូល លើសៀវភៅការងារដល់កម្មករ និយោជិតខ្មែរ សរុប ១៦១នាក់ ស្រី ៩៥នាក់
- បានផ្តល់ប័ណ្ណការងារជនបរទេស ចំនួន ៤៣៤នាក់ ស្រី ១៣៣នាក់ (ផ្តល់ប័ណ្ណការងារថ្មី និងទិដ្ឋាការចូល ២២នាក់ ស្រី ១១នាក់ និងពន្យាសុពលភាពលើប័ណ្ណការងារ ៤១២នាក់ ស្រី ១២២នាក់)
- បានពិនិត្យ លើការស្នើសុំកូតាប្រើប្រាស់ហត្ថពលកម្មបរទេស សរុបចំនួន១៤ក្រុមហ៊ុន។

▪ **ខេត្តកណ្តាល៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រសួងការងារដើម្បីចុះធ្វើអធិការកិច្ចការងារពិសេសចំនួន ៧លើក ស្មើនឹង៧សហគ្រាស គ្រឹះស្ថាន ចុះត្រួតពិនិត្យលើបែបបទ ស្តីពីសហគ្រាស និងលក្ខខណ្ឌការងារតាមរយៈបណ្តឹងរបស់កម្មករនិយោជិត។ ក្នុងនោះមានសហគ្រាស គ្រឹះស្ថាន ៤ ត្រូវបានក្រុមការងារធ្វើការដាក់កំហិត និងសហគ្រាស គ្រឹះស្ថាន ២ ត្រូវបានក្រុមការងាររៀបចំឯកសារត្រៀមផាកពិន័យ។

▪ **ខេត្តកំពង់ឆ្នាំង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះពង្រឹងវិធានការលើកកម្ពស់សុវត្ថិភាព និងសុខភាពការងារ របស់កម្មករនិយោជិតក្នុងអំឡុងពេលមានការប្រែប្រួលអាកាសធាតុក្នុងរដូវប្រាំង និងបានត្រួតពិនិត្យលក្ខខណ្ឌសុវត្ថិភាព សុខភាពការងារ និងពិនិត្យស្ថានភាពកំដៅតាមអគារនៅក្នុងក្រុមហ៊ុន ចំនួន ១៥ រោងចក្រ សហគ្រាស។

#### ក.៣.១. ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈរូបភាពរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) បានសម្ភាសន៍ជនបរទេស ដែលមកដាក់ពាក្យសុំចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរតាមផ្លូវច្បាប់ បានចំនួន ១៤៣នាក់ ស្រី៥នាក់ មាន១៧សញ្ជាតិ៖ ចិន ៨៥នាក់ស្រី១នាក់ កូរ៉េខាងត្បូង ២៦នាក់ស្រី២នាក់ អាម៉េរិក ៧នាក់ស្រី១នាក់ បារាំង៤នាក់ ម៉ាឡេស៊ី៤នាក់ អូស្ត្រាលី៣នាក់ កាណាដា២នាក់ អាល្លឺម៉ង់២នាក់ វៀតណាម ២នាក់ស្រី១នាក់ ថៃ១នាក់ អៀរឡង់១នាក់ ដាណឺម៉ាក១នាក់ ហ្វីលីពីន១នាក់ ប៉ាគីស្ថាន១នាក់ អង់គ្លេស១នាក់ ហូឡង់១នាក់ ស្លូវ៉ាគី១នាក់។ *និងវាយតម្លៃបញ្ជូនទៅក្រុមការងារបម្រុងច្រកចេញ-ចូលតែមួយចំនួន ១៣៧នាក់ ស្រី៣នាក់។*

### ក.៣.២. ការគ្រប់គ្រងស្ថិតិចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ និងជនបរទេស

❖ ការគ្រប់គ្រងស្ថិតិបច្ចុប្បន្នភាពចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ

▪ អគ្គស្នងការដ្ឋាននគរបាលជាតិ៖

• ទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុកទាំងស្របច្បាប់ មិនស្របច្បាប់ និងជាប់ការទាក់ទង រាជធានី ខេត្ត សរុបចំនួន៤០,១៩៥នាក់ ស្រី១៨,០៧៨នាក់ អនីតិជន៣២០នាក់ ស្រី១១៥នាក់ ក្នុងនោះ ៖

  ○ ស្របច្បាប់ចំនួន ៣៤,៦១២នាក់ ស្រី ១៥,៥៥៣នាក់ អនីតិជន ១៥៩នាក់ ស្រី ៤៩នាក់

  ○ មិនស្របច្បាប់ចំនួន ៥,៤៣៦នាក់ ស្រី ២,៤៧៩នាក់ អនីតិជន ១៣៤នាក់ ស្រី ៥៥នាក់

  ○ ជាប់ការទាក់ទងចំនួន ១៤៧នាក់ ស្រី ៤៦នាក់ អនីតិជន ២៧នាក់ ស្រី ១១នាក់។

• ទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់ពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ រាជធានី ខេត្ត សរុបចំនួន ១៤,៥០៨នាក់ ស្រី ៦,៨៣៩នាក់ អនីតិជន ៣៨១នាក់ ស្រី ១៣២នាក់។

▪ លេខាធិការដ្ឋាន គ.ខ.ប.ជ/គ.រ.ប.ជ៖ បានធ្វើស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេស និងបានវិលត្រឡប់មកវិញ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | រាជធានី ខេត្ត | ចំនួនពលករចំណាកស្រុក ទៅក្រៅប្រទេស | | | | ចំនួនពលករវិលត្រឡប់ ពីក្រៅប្រទេស | | | |
|---|---|---|---|---|---|---|---|---|---|
| | | ចំនួនពលករ | | អនីតិជន | | ចំនួនពលករ | | អនីតិជន | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | កណ្តាល | ៥,៩៣០ | ២,៩៧៦ | ១៧៥ | ៨៨ | ៩២១ | ៤២៤ | ៤១ | ២២ |
| ២ | បាត់ដំបង | ១៧៥ | ៦៦ | | | | | | |
| ៣ | សៀមរាប | ២២,២៦២ | ១០,២៤៩ | ១,១៦០ | ៥៦៦ | ២៦២ | ១១៩ | ១៦ | ០៩ |
| ៤ | កំពង់ឆ្នាំង | ១៣ | ០៦ | | | ៥៩ | ១២ | | |
| ៥ | កំពង់ចាម | ១២,៨១២ | ៥,៨៨៩ | | | ៧,៥២០ | ៣,៨២០ | ១៤២ | ៨៨ |
| ៦ | ព្រះសីហនុ | | | | | ៦២៧ | ២៤១ | | |
| ៧ | ព្រះវិហារ | | | | | ៦៧៤ | ៣០១ | ១១៥ | ៥២ |
| ៨ | ស្វាយរៀង | ៤,៩៩៣ | ២,៦៥៥ | | | ៤,០៥៩ | ១,៦៥៤ | | |
| ៩ | កោះកុង | ១,២២០ | ៦០៧ | ៩០ | ៣៥ | | | | |
| ១០ | ក្រចេះ | ១,៨៥១ | ៨៣៣ | | | ២,០៥៨ | ៨៨៩ | ៨៧ | ៣៥ |
| ១១ | កែប | ១,៩១៤ | ៩៨២ | | | | | | |
| ១២ | កំពង់ស្ពឺ | ៩៣៣ | ១៦៨ | | | | | | |
| ១៣ | ស្ទឹងត្រែង | ៥៩៤ | ៣១១ | ១១ | ០៧ | | | | |
| ១៤ | រតនៈគីរី | | | | | ៥៤០ | ២៣៧ | ២៥ | |
| ១៥ | ព្រៃវែង | ៨៧៧ | ៣៨៣ | ២៥ | ១៣ | ១២៧ | ៦៤ | ០៨ | ០២ |
| ១៦ | ត្បូងឃ្មុំ | ១២,៥៨៣ | ៥,៤៦៥ | ៧២ | ៣៩ | | | | |
| ១៧ | ឧត្តរមានជ័យ | ៩,១៧៦ | ៤,៦៨៩ | ០២ | | | | | |
| ១៨ | មណ្ឌលគិរី | ៨០ | ២៨ | ១៣ | ០៥ | | | | |
| | សរុបរួម | ៧៥,៤១៣ | ៣៥,៣០៧ | ១,៥៤៨ | ៧៥៣ | ១៦,៨៤៧ | ៧,៧៦១ | ៤៣៤ | ២០៨ |

❖ ការទទួលពលរដ្ឋខ្មែរចំណាកស្រុកដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់

**ស្ថិតិពលរដ្ឋខ្មែរដែលត្រូវអាជ្ញាធរបរទេសបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែន(កម្ពុជា-ថៃ-វៀតណាម)**

▪ **ខេត្តកោះកុង៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលពលរដ្ឋខ្មែរដែលអាជ្ញាធរថៃបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ចំនួន **៧លើក** មនុស្សចំនួន **២៦នាក់** ស្រី **៥នាក់**។

▪ **ខេត្តស្វាយរៀង៖** ក្រុមការងារជំនាញនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានទទួលពលរដ្ឋខ្មែររស់នៅតាមទីសាធារណៈនៅប្រទេសវៀតណាម និងប្រជាពលរដ្ឋដែលត្រូវចាញ់បោកមេខ្យល់ឆ្លងដែនទៅប្រទេសចិន ត្រូវបានអាជ្ញាធរវៀតណាមចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន **១លើក** មាន៤គ្រួសារ មនុស្សចំនួន ៤នាក់ ស្រី ៣នាក់។

▪ **ខេត្តបាត់ដំបង៖** កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកទាំង៤ សហការជាមួយសមត្ថកិច្ចថៃ បានទទួលប្រជាពលរដ្ឋខ្មែរ គ្មានលិខិតឆ្លងដែនត្រឡប់មកវិញចំនួន **១៩លើក** ទទួលពលករចំនួន **២,២៦៤នាក់** ស្រី ៨០៨នាក់ អនីតិជន **១៨៥នាក់** បានធ្វើការអប់រំ និងបញ្ជូនទៅលំនៅដ្ឋានវិញ។

❖ ការទទួលពលករនៅតាមមណ្ឌលទទួលពលករ

▪ **មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត** បានទទួលពលករខ្មែរចំណាកស្រុកដែលត្រូវអាជ្ញាធរថៃបញ្ជូនត្រឡប់មកកម្ពុជាវិញតាមច្រកអន្តរជាតិប៉ោយប៉ែត សរុបចំនួន **១៤២នាក់** (ប្រុស **៩១នាក់** ស្រី **៣៩នាក់** កុមារ **៧នាក់** កុមារី **៥នាក់**)។

▪ **មណ្ឌលទទួលពលករកំរៀង** បានទទួលពលករខ្មែរបញ្ជូនត្រឡប់ពីអាជ្ញាធរថៃ ចំនួន **១,៩៧៣នាក់** ក្នុងនោះស្ត្រីមាន **៧៨១នាក់** (ស្ត្រីមានកូនតូចមកជាមួយ **១៤១នាក់** និងស្ត្រីមានផ្ទៃពោះ **២០នាក់**) អនីតិជន **១០៣នាក់** (ដោយក្នុងនោះអនីតិជនជាស្ត្រី **៤៩នាក់**) និងជនមានពិការភាព **៥នាក់** (ស្ត្រី **២នាក់**)។

## គ.៤. កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

❖ ការផ្សព្វផ្សាយ

▪ **ខេត្តក្រចេះ៖** មន្ទីរឧស្សាហកម្ម និងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍៖ បានចុះផ្សព្វផ្សាយតាមបណ្តាមូលដ្ឋានជញ្ជីងគោន និងសិប្បកម្មបិតស្រា នៅក្នុងខេត្តក្រចេះ បានចំនួន៨មូលដ្ឋាន ស្តីពីការហាមឃាត់ប្រើប្រាស់ពលកម្មកុមារ ការកេងប្រវ័ញ្ច ការទប់ស្កាត់រាល់សកម្មភាពជួញដូរ និងប្រើហិង្សាលើបុគ្គលិកកម្មករ (ពិសេសកុមារ) មានបុគ្គលិកចំនួន **១៦នាក់** ស្រី **៥នាក់** និងអប់រំបុគ្គលិកដែលធ្វើការតាមបណ្តារោងចក្រសិប្បកម្ម ដែលមានកូនឱ្យបញ្ជូនកូនឱ្យចូលសិក្សាគ្រប់គ្នា។

▪ **ខេត្តព្រះសីហនុ៖** (អង្គការម្លប់តាប៉ាង)

- បានពង្រឹងសមត្ថភាពក្រុមកុមារ បណ្តាញនៅតាមឆ្នេរសមុទ្រចំនួន **៤៧នាក់** ស្រី **១៧នាក់** ដែលជាក្រុមបណ្តាញសម្រាប់ផ្តល់ព័ត៌មានសង្ស័យ លើការរំលោភបំពាន ការកេងប្រវ័ញ្ច និងការជួញដូរកុមារ
- បានធ្វើយុទ្ធនាការផ្សព្វផ្សាយពីសុវត្ថិភាពកុមារ ក្នុងសហគមន៍និងក្នុងវិស័យទេសចរណ៍ ក្នុងពិធីតាំងពិព័រណ៍ទេសចរណ៍ វប្បធម៌ និងពាណិជ្ជកម្ម សរុបចំនួន **២៥០នាក់**។

## គ.៥. ការលើកកម្ពស់ជីវភាព

❖ ការផ្តល់ព័ត៌មានការងារ និងបង្កើនកម្មវិធីសិក្សា សម្រាប់អាជីពការងារ និងវិជ្ជាជីវៈ

▪ ខេត្តសៀមរាប

- មជ្ឈមណ្ឌលការងារខេត្ត បានប្រមូលព័ត៌មានជ្រើសរើសកម្លាំងពលកម្មពីគ្រប់ប្រភព បានចំនួន **១៨៨កន្លែង**។ បានរៀបចំពិព័រណ៍ការងារចល័ត និងវេទិកាការងារ បានចំនួន **៣លើក** ដែលមានអ្នកចូលរួមសរុប

២,៥០០នាក់ ស្រី ១,២០០នាក់។ បានទទួលចុះឈ្មោះអ្នកស្វែងរកការងារធ្វើ ចំនួន ៤០នាក់ ស្រី ១៣នាក់ (ពលករ ១១នាក់ ស្រី ៤នាក់)។ បានផ្តល់ផ្គងនិងបញ្ជូនអ្នកស្វែងរកការងារធ្វើទៅឱ្យនិយោជក បានចំនួន ២៧៩នាក់ ស្រី ១៤១នាក់ (ពលករ ១៣៣នាក់ ស្រី ៦០នាក់)។ អ្នកទទួលបានការងារធ្វើសរុប ៦២នាក់ ស្រី ៣៥នាក់ (ពលករ ២៥នាក់ ស្រី១៣នាក់)។ ផ្តល់ការប្រឹក្សាអំពីអាជីពការងារ និងវិជ្ជាជីវៈដល់អ្នកស្វែងរកការងារធ្វើ បានចំនួន ២នាក់(ស្រី)។ បានចែកខិត្តប័ណ្ណអំពីព័ត៌មានទីផ្សារការងារ បានចំនួន ២,០០០ខិតប័ណ្ណ/កម្មវិធី។

- វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប បានចុះផ្សព្វផ្សាយនៅក្នុងកម្មវិធីជំរុំយុវវ័យ វេទិកាការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពិព័រណ៍មគ្គុទេសក៍អាជីព និងការសិក្សា ពិព័រណ៍ការងារ និងកម្មវិធីវិថីឆ្ពោះទៅកាន់ការអភិវឌ្ឍការងារ និងវិជ្ជាជីវៈ នៅតាមវិទ្យាល័យ បាន ១៨លើក ដែលមានអ្នកចូលរួមសរុប ៤,៦១៨នាក់ ស្រី ២,៩៩៤នាក់។

- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍ខេត្ត បានជំរុញ និងលើកទឹកចិត្តដល់សហគ្រិន ដោយបានណែនាំពីចំណុចដែលត្រូវកែលម្អ និងចំណុចត្រូវធ្វើបន្ថែមទៀត ដើម្បីផលិតកម្មមានដំណើរការ និងបានជួយកម្មករឱ្យមានការងារធ្វើនៅនឹងកន្លែង នៅក្នុងកម្មវិធីចុះអធិការកិច្ចតាមដាន នៅតាមមូលដ្ឋានអាជីវកម្ម បានចំនួន១៨មូលដ្ឋាន សរុបមនុស្សចំនួន ១២៦នាក់ ស្រី ៥៤នាក់។

▪ **ខេត្តព្រៃវែង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរកការងារឱ្យពលករវិលត្រឡប់ពីប្រទេសថៃ បានចំនួន ១៨,៥២១នាក់ ស្រី ៨,០៣០នាក់ ក្នុងចំណោមពលករចំនួន ២២,១៨៩នាក់ ស្រី ៩,៥៧៥នាក់ ក្នុងខែមីនា មានចំនួន ៩នាក់ ស្រី ៤នាក់។

▪ **ខេត្តពោធិ៍សាត់៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពលករដែលត្រឡប់មកពីប្រទេសថៃទទួលបានការងារធ្វើមានចំនួន ៤,៩៩៧នាក់ ស្រី ២,៣២២នាក់ ក្នុងខែមីនាមានចំនួន ៣២០នាក់ ស្រី ២៨នាក់។

▪ **ខេត្តព្រះវិហារ៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្សព្វផ្សាយឱកាសការងារដល់បងប្អូនប្រជាពលរដ្ឋកំពុងស្វែងរកការងារធ្វើ តាមរយៈហ្វេសប៊ុកផេក និងគ្រុបតេលេក្រាមមន្ទីរការងារ ជាមួយសហគ្រាសគ្រឹះស្ថានក្នុងខេត្ត និងចែកខិត្តប័ណ្ណផ្សព្វផ្សាយចំនួន ១៤សន្លឹក អ្នកទទួលបាន ៤៤១នាក់ ស្រី ១២៦នាក់។

▪ **ខេត្តកំពង់ចាម**

- មន្ទីរកិច្ចការនារីខេត្ត បានចូលរួមវេទិកាការងារ និងយុទ្ធនាការចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីឱ្យអ្នកចូលរួមទាំងអស់ដឹងពីឱកាសការងារ នៅក្នុងប្រទេសបង្ហាញឱ្យសិស្សនិស្សិត និងប្រជាពលរដ្ឋយល់ដឹងពីសារៈប្រយោជន៍ និងដំណើរការ នៃការចុះបញ្ជីសម្រាប់អ្នកប្រកបមុខរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីផ្សាភ្ជាប់សេវាការងារ NEA សម្រាប់វិនិយោគ មានអ្នកចូលរួមចំនួន ៣០៤នាក់ ស្រី ១៤៥នាក់។

- ក្រុមការងារទេសន្តរប្រវេសន៍ នៃមន្ទីរការងារ បានសហការជាមួយអង្គការភ្នំស្រី ដើម្បីអភិវឌ្ឍន៍ និងវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម ចុះផ្សព្វផ្សាយពីការស្វែងរកការងារធ្វើក្នុងស្រុក និងវគ្គបណ្តុះបណ្តាលបច្ចេកទេសនៅភូមិសំបូរ ឃុំសូភាស ស្រុកស្ទឹងត្រង់ និងឃុំខ្វិតធំ ស្រុកព្រៃឈរ ដែលមានអ្នកចូលរួមសរុបចំនួន ២៤៥នាក់ ស្រី ១៥៧នាក់។

▪ **ខេត្តបាត់ដំបង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមកម្មវិធីវេទិកាការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្វែងរកការងារជូនបងប្អូនដែលត្រឡប់ពីប្រទេសថៃ ក្នុងយុទ្ធនាការខ្មែរជួយរកការងារ និងផ្តល់ការងារឱ្យខ្មែរ នៅស្រុកកំរៀង ស្រុកភ្នំព្រឹក ស្រុកសំពៅលូន និងស្រុកថ្មគោល មានអ្នកចូលរួមចំនួន ៣,០៤៩នាក់ ស្រី ១,៩៨១នាក់ មានអ្នកជាប់សម្ភាសន៍ការងារបឋម ៣៩០នាក់ ស្រី ២៤៦នាក់។

❖ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបំណិនជីវិត

▪ ខេត្តស្វាយរៀង៖ មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រុមហ៊ុនចំនួន៥ បើកវគ្គបណ្តុះបណ្តាលដោយបានបញ្ជ្រាបការយល់ដឹងអំពីចំណាកស្រុកប្រកបដោយសុវត្ថិភាព រួមបញ្ចូលជាមួយនូវប្រធានបទ ស្តីពីបំនិនជីវិត អាហារូបត្ថម្ភ គ្រឿងញៀន និងសុវត្ថិភាពចរាចរណ៍ ការគ្រប់គ្រងសារធាតុគីមី ភាពជាអ្នកដឹកនាំក្រុមល្អ ដើម្បីបង្កើនផលិតភាពផលិតផល ច្បាប់ស្តីពីការងារសុខភាព និងសុវត្ថិភាពការងារ និងការជួយសង្គ្រោះបឋមចំនួន ៥វគ្គ អ្នកចូលរួមចំនួន ១១៥នាក់ ស្រី៧៧នាក់។

▪ ខេត្តព្រះសីហនុ៖ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត បានចុះផ្សព្វផ្សាយចំណេះជំនាញជូនតា ស្តីពីសិប្បកម្មតម្បាញផ្តៅ ចំនួន ២លើក នៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសក្រុងព្រះសីហនុ និងវិទ្យាល័យហ៊ុន សែន មិត្តភាព មានអ្នកចូលរួមចំនួន ១៩៧នាក់ ស្រី១២៩នាក់។

## ខ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### ខ.១. ការងារអនុវត្តច្បាប់

❖ **ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ**

ក្រុមការងារការអនុវត្តច្បាប់ នៃ គ.ជ.ប.ជ ដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួ ១៩/១៧ករណី (កើន ២ករណី) ស្មើនឹង១១,៧៦%

- យាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត ចំនួន ៣៤នាក់ ស្រី៧នាក់ មានជនបរទេស ៧នាក់ ស្រី១នាក់ (ជនជាតិចិន)។
- សង្គ្រោះជនរងគ្រោះចំនួន ៥៣នាក់ ស្រី៣៧នាក់ ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ៨នាក់(ស្រី) អាយុ ១៥-១៧ឆ្នាំ ៩នាក់(ស្រី) អាយុ១៨ឆ្នាំឡើង ៣៦នាក់ ស្រី២០នាក់ និងបានបញ្ជូនទៅមន្ទីរសង្គមកិច្ច ៣២នាក់ និងទៅគ្រួសារ ២១នាក់។

ក្នុងនោះចែកជា៖

**<u>ករណីអំពើជួញដូរមនុស្ស</u>**

បង្ក្រាបបាន ១០/០៩ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ១១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ១៨នាក់ ស្រី៨នាក់ មានអាយុ១៥-១៧ឆ្នាំ ១នាក់(ស្រី) អាយុ១៨ឆ្នាំឡើង ១៧នាក់ ស្រី៧នាក់ បានបញ្ជូនទៅមន្ទីរសង្គមកិច្ច ២នាក់ និងគ្រួសារ ១៦នាក់។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | ជនរងគ្រោះ(ស្រី) |
|---|---|---|---|
| ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០៧ | ០៨ | ១៤(០៦) |
| អំពើនាំឆ្លងដែន | ០១ | ០១ | ០២ |
| ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០២ | ០២ | ០២(០២) |
| *សរុប* | *១០ករណី* | *១១នាក់* | *១៨(០៨)នាក់* |

**<u>ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ</u>**

បង្ក្រាបបាន ០៩/០៨ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ២៣នាក់ ស្រី៧នាក់ ជនជាតិចិន ៧នាក់ ស្រី ១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ៣៥នាក់(ស្រី២៩នាក់) មានអាយុក្រោម១៥ឆ្នាំ៨នាក់(ស្រី) អាយុ១៥-១៧ឆ្នាំ ៩នាក់(ស្រី) អាយុ១៨ឆ្នាំឡើង ៣៦នាក់ ស្រី២០នាក់ បានបញ្ជូនទៅមន្ទីរសង្គមកិច្ច ៣២នាក់ និងគ្រួសារ ២១នាក់។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ(ស្រី) |
|---|---|---|---|---|
| ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ០២ | ០៨ | ចិន៤ | ០៧(០១) |
| សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០២ | ០៦ | ចិន៣ | ១៦(១៦) |
| ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ០១ | ០៥ | | ០៨(០៨) |
| អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៤ | ០៤ | | ០៤(០៤) |
| *សរុប* | *០៩ករណី* | *២៣នាក់* | *០៧នាក់* | *៣៥(២៩)នាក់* |

## គ. កិច្ចការពារជនរងគ្រោះ

### គ.១. ការទទួល និងសម្ភាសពលករបញ្ជូនទាំងក្នុងប្រទេស និងត្រឡប់ពីក្រៅប្រទេស

▪ ក្រុមការងារការពារជនរងគ្រោះ នៃ គ.ជ.ប.ជ ដឹកនាំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ មន្ទីរសង្គមកិច្ចរាជធានី ខេត្ត និងអង្គការដៃគូ តាមរយៈនាយកដ្ឋានគាំពារជនរងគ្រោះនៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច បានទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្សក្នុងប្រទេស និងក្រៅប្រទេសចំនួន ៩នាក់(ស្រី ៤នាក់ កុមារី៥នាក់) ក្នុងនោះ៖

- ក្នុងប្រទេស ជនជាតិខ្មែរ ១នាក់(កុមារី) ករណីរំលោភបំពានផ្លូវភេទ
- ក្រៅប្រទេសចំនួន ៨នាក់ (ស្រី៤នាក់ កុមារី៤នាក់) ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ ពីចិន ៥នាក់ (ស្រី៣នាក់ កុមារី២នាក់) និងវៀតណាម ៣នាក់(ស្រី១នាក់ កុមារី២នាក់)។

➢ *បានធ្វើការកំណត់អត្តសញ្ញាណពីមន្ត្រីនគរបាលយុត្តិធម៌ជំនាញទាំងអស់។*

### គ.២. ការផ្តល់សេវាគាំទ្រនិងស្តារនីតិសម្បទា

ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស បានបញ្ជូនទៅស្តារនីតិសម្បទា នៅមជ្ឈមណ្ឌលរបស់អង្គការដៃគូចំនួន ៩នាក់(ស្រី ៤នាក់ កុមារី៥នាក់) ក្នុងនោះ៖ អង្គការរតនៈអ៊ីនធើណេសិនណល ៦នាក់(ស្រី៤នាក់ កុមារី២នាក់) អង្គការសម្ព័ន្ធចាប់ដៃ ២នាក់(កុមារី) និងអង្គការអាហ្វេស៊ីបកម្ពុជា ១នាក់ (កុមារី)។

### គ.៣. ការធ្វើមាតុភូមិនិវត្តន៍

ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រំលោភបំពានផ្លូវភេទ ដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍ ទៅប្រទេសដើមវិញ ចំនួន ៣នាក់(ប្រុស២នាក់ កុមារី១នាក់) មានមីយ៉ាន់ម៉ា ១នាក់(ប្រុស) ចិន ១នាក់(ប្រុស) និងអាឡឺម៉ង់ ១នាក់(កុមារី)។

### គ.៤. ការធ្វើសមាហរណកម្ម

បានសមាហរណកម្មជនរងគ្រោះត្រឡប់ទៅសហគមន៍ ចំនួន២៦នាក់(ប្រុស១នាក់ ស្រី៨នាក់ កុមារ២នាក់ កុមារី១៥នាក់)។

### គ.៥. ការតាមដានជនរងគ្រោះ

បានតាមដានជនរងគ្រោះ ចំនួន ២៨៨នាក់(ប្រុស១នាក់ ស្រី៨៨នាក់ កុមារ៤២នាក់ កុមារី១៥៧នាក់)។

### គ.៦. ការបិទករណីជនរងគ្រោះ

បានបិទករណី ជនរងគ្រោះ ចំនួន ១៣នាក់(ស្រី៦នាក់ កុមារី៧នាក់)។

## ឃ. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចសហប្រតិបត្តិការ

### ឃ.១. លិខិតបទដ្ឋានគតិយុត្ត

▪ ខេត្តតាកែវ៖ បានចេញសេចក្តីសម្រេចចំនួន ២ច្បាប់ ក្នុងនោះសេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត(គ.ខ.ប.ជ)លេខ ០៤៧/២៦ ចុះថ្ងៃទី៦ ខែមីនា

ឆ្នាំ២០២៦ និងចេញសម្រេចលេខ ០២១/២៦ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៦ ស្តីពីការកែសម្រួលសមាសភាពលេខាធិការដ្ឋានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ខ.ប.ជ)ខេត្តតាកែវ។

## III. ការលើកកម្ពស់សមត្ថភាព និងការដឹកនាំសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការបណ្តុះបណ្តាល

❖ ការបណ្តុះបណ្តាលក្នុងប្រទេស

| ល.រ | សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | ចំនួនរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានបើកវគ្គបណ្តុះបណ្តាលៈ ស្តីពីកិច្ចការកុមារក្នុងបរិបទទេសន្តរប្រវេសន៍ និងផ្សាយផ្សាយសេចក្តីណែនាំស្តីពីការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរប្រវេសន៍និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ ចំនួន ០២វគ្គ នៅខេត្តស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ក្រចេះ ព្រះវិហារ មនុស្ស ១៣៤នាក់ ស្រី៦៣នាក់ និងនៅខេត្តកំពង់ចាម ត្បូងឃ្មុំ កំពង់ធំ ព្រៃវែង ស្វាយរៀង មនុស្ស ១៥៣នាក់ ស្រី៨១នាក់។ | ០២ | ២៨៧ | ១៤៤ |
| ២ | ខេត្តសៀមរាបៈ មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត និងសាខាកាកបាទក្រហមកម្ពុជាខេត្ត បានបណ្តុះបណ្តាល ស្តីពីច្បាប់ការងារ១លើក និងស្តីពីការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទស្ត្រីនិងកុមារ តាមប្រព័ន្ធអនឡាញ ១លើក។ | ០២ | ៧៣ | ៤៦ |
| ៣ | ខេត្តបាត់ដំបងៈ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ចការងារ។ | ០១ | ២៥ | ០៩ |
| ៤ | ខេត្តស្ទឹងត្រែងៈ លេខាធិការដ្ឋាន គ.ខ.ប.ជ បានសម្របសម្រួល គណៈកម្មាធិការជាតិ គ.ជ.ប.ជ ដោយមានការកិច្ចសហការពី អង្គការ UNICEF បើកវគ្គបណ្តុះបណ្តាល កិច្ចការពារកុមារក្នុងបរិបទទេសន្តរប្រវេសន៍ និងផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍។ | ០១ | ១០៣ | ៦៣ |
| ៥ | ខេត្តកំពង់ចាមៈ លេខាធិការដ្ឋាន គ.ខ.ប.ជ បានសម្របសម្រួល គណៈកម្មាធិការជាតិ គ.ជ.ប.ជ វគ្គបណ្តុះបណ្តាល ស្តីពីការផ្សព្វផ្សាយសេចក្តីណែនាំ និងការប្រមូលទិន្នន័យពលរដ្ឋទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ដល់មន្ត្រី គ.រ.ប.ជ/គ.ខ.ប.ជ ខេត្តទាំង៥ កំពង់ចាម ត្បូងឃ្មុំ កំពង់ធំ ព្រៃវែង និងស្វាយរៀង ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ | ០១ | ១៣១ | ៦៧ |
| ៦ | អង្គការសាម៉ារីតាន់ភីសសង្គ្រោះអន្តរជាតិ (ខេត្តបន្ទាយមានជ័យ) បានផ្តល់វគ្គបណ្តុះបណ្តាលដល់អាជ្ញាធរ និងអ្នកពាក់ព័ន្ធអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងទប់ស្កាត់ការជួញដូរមនុស្ស។ | ០១ | ២៤ | ១៣ |
| | *សរុប* | *០៨វគ្គ* | *៦៤៣នាក់* | *៣៥២នាក់* |

#### ក.២. សិក្ខាសាលា

❖ **សិក្ខាសាលាក្នុងប្រទេស**

▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសហការជាមួយអង្គការ WORLD HOPE International រៀបចំសិក្ខាសាលាបើកវគ្គបណ្តុះបណ្តាល អំពី «ផ្ទះមានសុវត្ថិភាព សុខមាលភាពដល់គ្រួសារប្រឆាំងទៅនិងការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ» ក្រោមអធិបតីភាព ឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច នៅភោជនីយដ្ឋាន ទន្លេបាសាក់២ មានអ្នកចូលរួមចំនួន ៥៥នាក់ ស្រី ២៧នាក់។

▪ ខេត្តបន្ទាយមានជ័យៈ មន្ទីរកិច្ចការនារីខេត្ត ដោយមានការគាំទ្រថវិកា PB បានបើកវគ្គសិក្ខាសាលាស្តីពីទប់ស្កាត់ការជួញដូរមនុស្ស ចំនួន ១វគ្គ មានអ្នកចូលរួមចំនួន ២១នាក់ ស្រី ១៤នាក់។

▪ ខេត្តរតនគិរីៈ បានសហការជាមួយ គ.ក.ស.ក ខេត្ត ធ្វើសិក្ខាសាលាស្តីពីអនីតិជនទំនាស់នឹងច្បាប់ និងវិធានការការពារ កែប្រែ និងស្តារនិតិសម្បទា ចំនួន ១លើក មានអ្នកចូលរួមចំនួន ១៣៦នាក់ ស្រី ៥៦នាក់។

❖ **សិក្ខាសាលាក្រៅប្រទេស**

▪ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចាត់បញ្ជូន លោកស្រីវរសេនីយ៍ឯក **ថោង សុវត្ថី** ប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ ក្នុងនាមជាសមាជិក ផែនប្រឆាំងការជួញដូរ មនុស្ស នៃក្រុមការងារ SOMTC-កម្ពុជា ទៅចូលរួមសិក្ខាសាលាអាស៊ាន លើកទី២ ស្តីពី Monitoring and Reporting MERL Framework of the Bohol TIP Work Plan 2.0 រៀបចំដោយ SOMTC-Philippines ក្នុងនាមជា Voluntary Lead Shepherd នៅប្រទេសហ្វីលីពីន។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. កិច្ចប្រជុំ

❖ **ការរៀបចំកិច្ចប្រជុំនៅក្នុងប្រទេស**

▪ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំកិច្ចប្រជុំ ចំនួន **៧**លើក មានអ្នកចូលរួមចំនួន **៥៧៤**នាក់ ស្រី **១៧២**នាក់ ក្នុងនោះ៖

- កិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ និង លើកទិសដៅការងារឆ្នាំ២០២៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ គ.ជ.ប.ជ** ដោយមានសមាសភាពអញ្ជើញចូលរួមពី ឯកឧត្តម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការនគរបាលជាតិ ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ តំណាង ក្រសួង ស្ថាប័ន និងអង្គភាព ជាសមាជិក ក្នុងរចនា សម្ព័ន្ធ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អគ្គាធិការ អគ្គនាយក អគ្គនាយករង អគ្គស្នងការរងនគរបាលជាតិ មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ប្រធាន អនុប្រធាននាយកដ្ឋាន តំណាងក្រសួង ស្ថាប័ន ឯកឧត្តម លោកជំទាវ អភិបាល អភិបាលរង នៃគណៈអភិបាលរាជធានី ខេត្ត ស្នងការ ស្នងការរង នៃស្នងការដ្ឋាននគរបាល រាជធានី ខេត្ត ព្រមទាំងអង្គការដៃគូ សរុបប្រមាណ **៥២០**រូប ស្រី **១៦១**រូប នៅទីស្តីការក្រសួងមហាផ្ទៃ។

- កិច្ចប្រជុំកម្រិតបច្ចេកទេសរៀបចំមេរៀនគោលសម្រាប់បណ្តុះបណ្តាលសៀវភៅ ស្តីពីក្របខ័ណ្ឌ តាមដាន វាយតម្លៃ និងសិក្សាដកបទពិសោធន៍ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្ស ២០២៤-២០២៨ ចំនួន **២**លើក សមាសភាពចូលរួម ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប ប្រធានក្រុមជំនួយកិច្ចការ តំណាងអង្គការIJM និងតំណាងអង្គការASEAN-ACT សរុបចំនួន **២៧**នាក់ ស្រី **៤**នាក់ នៅបន្ទប់ប្រជុំ គ.ជ.ប.ជ។

- កិច្ចប្រជុំពិភាក្សាលើក្របខ័ណ្ឌតាមដានវាយតម្លៃ និងសិក្សាដកបទពិសោធន៍ក្នុងការអនុវត្តផែនការ យុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រវាងក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាមួយ តំណាងអង្គការ ASEAN-ACT ចំនួន **១**លើក អ្នកចូលរួមចំនួន **៧**នាក់ ស្រី **២**នាក់ នៅបន្ទប់ប្រជុំ គ.ជ.ប.ជ។

- កិច្ចប្រជុំពិភាក្សារបស់ក្រុមការងារបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងតំណាងអង្គការ UNICEF ប្រចាំនៅកម្ពុជា ស្តីពីភារកិច្ចដែលត្រូវអនុវត្តទៅថ្ងៃមុខ បន្តតាមផែនការសកម្មភាព នៃកិច្ចសហការក្នុងការ អនុវត្តគម្រោងប្រមូលទិន្នន័យផលប៉ះពាល់កុមារ ក្នុងបរិបទទេសន្តរប្រវេសន៍ ចំនួន **១**លើក អ្នកចូលរួមចំនួន **៦**នាក់ ស្រី **១**នាក់ នៅបន្ទប់ប្រជុំ គ.ជ.ប.ជ។

- កិច្ចប្រជុំផ្ទៃក្នុង ស្តីពីការត្រៀមរៀបចំផ្សព្វផ្សាយរបាយការណ៍ជាតិ ការងារប្រយុទ្ធប្រឆាំងអំពើជួញ ដូរមនុស្ស ឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ ចំនួន **១**លើក អ្នកចូលរួមចំនួន **៧**នាក់ **៣**នាក់ និងកិច្ច

ប្រជុំកែសម្រួលសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់ របស់អង្គភាពការពារកុមារ CPU ចំនួន ១លើក អ្នកចូលរួមចំនួន ៧នាក់ ស្រី ២នាក់។

▪ ខេត្តសៀមរាប៖ លេខាធិការដ្ឋាន គ.ខ.ប.ជ និងក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ បានរៀបចំកិច្ចប្រជុំប្រចាំខែ និងកិច្ចប្រជុំពាក់ព័ន្ធ ដើម្បីតាមដាន ពិនិត្យ ពិភាក្សារកដំណោះស្រាយលើភាពប្រឈមនានាពាក់ព័ន្ធនឹងបញ្ហាអំពើជួញដូរមនុស្ស និងកិច្ចការពារកុមារ សរុបចំនួន ១៥លើក មានអ្នកចូលរួមសរុប ៤៤៨នាក់ ស្រី ២២៦នាក់។

▪ ខេត្តព្រៃវែង៖ រដ្ឋបាលខេត្ត បានរៀបចំកិច្ចប្រជុំគណៈបញ្ជាការឯកភាព ក្រោមអធិបតីភាព ឯកឧត្តម សួន សុម៉ាលីន អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ដោយមានសមាសភាពចូលរួមសរុបចំនួន ៣៨១រូប។

▪ ខេត្តកំពង់ចាម៖ លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៦ ជាមួយក្រុមការងារជំនាញ ក្រោមអធិបតីភាព លោកជំទាវ **ប៉ាង ដានី** អភិបាលរង នៃគណៈអភិបាលខេត្តកំពង់ចាម ចំនួន ១លើក សមាសភាពចូលរួមចំនួន ៥៧នាក់ ស្រី ៣៨នាក់។

▪ ខេត្តតាកែវ៖ លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៦ ចំនួន ១លើក របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទទួលស្គាល់សមាសភាព ថ្នាក់ក្រោមជាតិ អ្នកចូលរួមចំនួន ២៧នាក់ ស្រី ១១នាក់ ធ្វើនៅសាលប្រជុំទីចាត់ការផែនការវិនិយោគខេត្ត។

▪ ខេត្តព្រះវិហារ៖ លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំប្រចាំខែកុម្ភៈ និងខែមីនា ឆ្នាំ២០២៦ ចំនួន ២លើក អ្នកចូលរួមចំនួន ២១នាក់ ស្រី ៩នាក់។

### ខ.២. ទស្សនកិច្ច

▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំក្រុមការងារ គ.ជ.ប.ជ ៖

○ ធ្វើទស្សនកិច្ចនៅមណ្ឌលរបស់ អង្គការការីតាសកម្ពុជា ដើម្បីពិនិត្យ និងស្វែងយល់ អំពីដំណើរការនៃការផ្តល់ការគាំទ្រ ដល់ជនរងគ្រោះ នៅភូមិក្តុល សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល

○ ចុះបំពេញទស្សនៈកិច្ចនៅមណ្ឌលថែទាំរបស់ អង្គការដៃកម្ពុជា(ARM) នៅខេត្តសៀមរាប។

### ខ.៣. ជំនួបពិភាក្សាការងារ

▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំប្រតិភូ គ.ជ.ប.ជ ទទួលជំនួបពិភាក្សាការងារជាមួយ៖

- លោកស្រី Jane Duke ឯកអគ្គរាជទូត សហព័ន្ធអូស្ត្រាលី ដើម្បីពិភាក្សាអំពីបញ្ហាជួញដូរមនុស្ស ការរត់ពន្ធមនុស្ស និងបញ្ហាទាសភាពសម័យទំនើប នៅទីស្តីការក្រសួងមហាផ្ទៃ

- អង្គការ កម្មវិធីអាស៊ានអូស្ត្រាលី ប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) ដើម្បីពិភាក្សាការងាររៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- អង្គការ JICA អំពីលទ្ធផល នៃការអនុវត្តសាកល្បង លើការប្រើប្រាស់ គោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្របដែលបានកែសម្រួលរួច នៅទីស្តីការក្រសួងមហាផ្ទៃ។

▪ ខេត្តសៀមរាប៖ លេខាធិការដ្ឋាន គ.ខ.ប.ជ បានជួបពិភាក្សាការងារជាមួយ អង្គការមូលនិធិអន្តរជាតិហាការ និងម្ចាស់ជំនួយដើម្បីស្វែងរកអំពីយន្តការ និងកិច្ចសហការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងកិច្ចការពារកុមារពីការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ។

▪ ខេត្តកណ្តាល៖ រដ្ឋបាលក្រុងសំពៅពូន បានចូលរួមកិច្ចប្រជុំជំនួបពិភាក្សាជាមួយ អង្គការ ខេមរ អភិវឌ្ឍន៍សហគមន៍ ដើម្បីពិគ្រោះយោបល់ក្នុងការកសាងគម្រោងពង្រឹងសមត្ថភាពដល់ ជនបង្គោលតាមភូមិឱ្យយល់ដឹងអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងល្បិចកលជនឆបោក និងដើម្បីការពារប្រជាពលរដ្ឋក្នុងភូមិ។

## គ. ការងារសម្របសម្រួល

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត បានរៀបចំដឹកនាំសម្របសម្រួល និងចូលរួមកិច្ចប្រជុំនានា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សរុបចំនួន ៩០លើក មានអ្នកចូលរួមចំនួន ៣៣១នាក់ ស្រី ១០៦នាក់ ក្នុងនោះមាន គ.ជ.ប.ជ ៧០លើក និងគ.ខ.ប.ជ ២០លើក។ ( ឧបសម្ព័ន្ធ)

# IV. ការសន្និដ្ឋានវាយតម្លៃ

## ក. ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែងរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការកំណត់យកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាអាទិភាពមួយក្នុងចំណោមអាទិភាពនៃផែនការដែលត្រូវយកចិត្តទុកដាក់ គឺជាថាមពលជំរុញចិត្តឱ្យគ្រប់សមាសភាពក្នុងសង្គមទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ និងដៃគូ ជាតិ និងអន្តរជាតិ ឱ្យរឹតតែប្រឹងប្រែងទ្វេឡើងទៀត
- ច្បាប់ គោលនយោបាយ វិធានការ អនុសាសន៍របស់ប្រមុខដឹកនាំទាំងក្នុងនីតិកាលចាស់ និងថ្មី នៅតែមានគុណតម្លៃសម្រាប់ការអនុវត្ត ជាមូលដ្ឋានបង្អែក និងជាប្រទីបបំភ្លឺផ្លូវសម្រាប់ការកំណត់ការងារជាយុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្ស
- សន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត នៅតែមានតម្លៃជាកិច្ចសហប្រតិបត្តិការទូលំទូលាយលើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងអំពើពាក់ព័ន្ធដទៃទៀត
- រចនាសម្ព័ន្ធនៃយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាកម្លាំងស្នូលក្នុងការអនុវត្តការងារ តាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន បានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធទាំងឡាយក្នុងសង្គមកម្ពុជា
- ការចូលរួមឧបត្ថម្ភគាំទ្រពីអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ វិស័យឯកជន និងកិច្ចសហការក្នុងការបំពេញភារកិច្ចតាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព គឺជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុបសម្រាប់រួមគ្នាធ្វើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដ៏មានសក្តានុពល។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម មួយចំនួនដូចជា៖

- ទាមទារការយកចិត្តទុកដាក់បន្ថែមទៀត លើការចាត់តាំងមន្ត្រីទទួលបន្ទុកឱ្យបានជាក់លាក់ លើការងាររបាយការណ៍ ការងារផែនការ ការងារសម្របសម្របសម្រួល ការងាររដ្ឋបាលហិរញ្ញវត្ថុ សម្រាប់អនុវត្តយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមក្រសួងស្ថាប័ន មន្ទីរអង្គភាពនីមួយៗ ចៀសវាងការផ្លាស់ប្តូរញឹកញាប់ ឬគ្មានអ្នកទទួលខុសត្រូវច្បាស់លាស់ នាំឱ្យធ្វេសប្រហែស ១៥

- ត្រូវការពិភាក្សាបន្ថែម លើការកំណត់ឯកតាសម្រាប់ទិន្នន័យនៃរបាយការណ៍ ឧទាហរណ៍ ពាក្យថាជនរងគ្រោះ ជនងាយរងគ្រោះ ជនសង្ស័យថារងគ្រោះ,,, ដែលធ្វើឱ្យការបូកសរុប ទាំងបរិមាណ និងគុណភាព មិនទាន់ស៊ីចង្វាក់គ្នា
- ជនល្មើសមានកលល្បិចជ្រៀតចូលធ្វើសកម្មភាពខុសច្បាប់ និងអូសទាញមនុស្សឱ្យរងគ្រោះជាបន្តបន្ទាប់
- ខ្វះវិធីសាស្ត្រ និងសង្គតិភាពនៃសារអប់រំ ដែលមានប្រសិទ្ធភាព និងអាចបង្ការទប់ស្កាត់បាននូវអំពើជួញដូរ និងកេងប្រវ័ញ្ចគ្រប់ទម្រង់។

**គ. សេចក្តីសន្និដ្ឋាន និងសំណូមពរ**

បទល្មើសជួញដូរមនុស្ស និងបទល្មើសដទៃទៀត មានភាពប្រទាក់ក្រឡាគ្នា កាន់តែស្មុគស្មាញ និងរីកសាយ ឆាប់រហ័ស អាស្រ័យដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបជាមធ្យោបាយសម្រាប់បង្កើនប្រសិទ្ធភាពបទល្មើស ឱ្យកាន់តែមានកម្រិតខ្ពស់ និងអាចខ្ពស់ជាងបច្ចេកទេសដែលសមត្ថកិច្ចប្រើប្រាស់បច្ចុប្បន្ន។ ករណីខ្លះ ជនល្មើស និងជនរងគ្រោះ ជាមនុស្សតែមួយ និងមានបណ្តាញប្រទាក់ក្រឡាពីកន្លែងមួយ ទៅកន្លែងមួយ ពីប្រទេសមួយ ទៅប្រទេសមួយ។ ករណីភាគច្រើន មិនពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សទេ តែបង្កប់នូវបទល្មើសផ្សេងទៀត មានជាអាទិ៍ អំពើឆបោក អំពើចាប់ជំរិត គំនុំ ទំនាស់ការងារ ប្រព្រឹត្តខុសច្បាប់ការងារ ខុសច្បាប់អន្តោប្រវេសន៍ ការបន្លំជាជនរងគ្រោះ ដើម្បីគេចពីសំណាញ់ច្បាប់ ជាដើម។

យុទ្ធសាស្ត្របង្ការទប់ស្កាត់ នៅតែជាអាទិភាព ដែលអាចការពារមិនឱ្យមនុស្សគ្រប់វ័យពីដំណាក់កាលដំបូង ដោយមិនរង់ចាំឱ្យដល់ដំណាក់កាលរងគ្រោះ ព្រោះវានឹងធ្វើឱ្យខូចខាត ទាំងធនធានមនុស្ស ធនធានថវិកា ពេលវេលា ទំនាក់ទំនងសង្គម និងការអភិវឌ្ឍន៍គ្រប់វិស័យ។

ការពង្រឹងស្ថាប័ន សមត្ថភាពជំនាញ និងឥរិយាបថមន្ត្រីគ្រប់ឋានានុក្រម និងការពិនិត្យឡើងវិញ នូវនីតិវិធីច្បាប់ ក៏ដូចជាកិច្ចសហការរវាងវិស័យពាក់ព័ន្ធ ប្រទេសពាក់ព័ន្ធ ក្នុងតំបន់ និងជាអន្តរជាតិ នៅតែមានភាពចាំបាច់ មិនអាចខ្វះបាន ក្នុងការកាត់បន្ថយ ឈានទៅលុបបំបាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធ។

ជាសំណូមពរ ចំពោះ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ក្នុងយន្តការនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖

- គប្បីរៀបចំចាត់តាំងមន្ត្រីទទួលខុសត្រូវ បំពេញតាមរចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់ថ្នាក់ឱ្យបាន ច្បាស់លាស់ ប្រកបដោយការទទួលខុសត្រូវ រួមទាំងមន្ត្រីលេខាធិការដ្ឋាន ទទួលបន្ទុក ការងាររបាយការណ៍ ផែនការ និងការងាររដ្ឋបាល ហិរញ្ញវត្ថុ ដើម្បីងាយស្រួលដល់ការរៀបចំវគ្គបណ្តុះបណ្តាលតាម ជំនាញសម្រាប់ការអនុវត្តការងារឲ្យទទួលបានប្រសិទ្ធភាពខ្ពស់
- ពង្រឹងកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងកិច្ចប្រជុំគណៈកម្មាធិការ និងលេខាធិការដ្ឋាន ខេត្ត ក្រុង ស្រុក ខណ្ឌ (គ.ខ/រ.ប.ជ) ឱ្យបានទៀងទាត់ប្រចាំខែ ឬត្រីមាស ដើម្បីបូកសរុបរបាយការណ៍ វាយតម្លៃលើសកម្មភាព និងលទ្ធផលនៃការអនុវត្តផែនការតាមយុទ្ធសាស្ត្រនីមួយៗ។

## V. ទិសដៅខែមេសា ឆ្នាំ ២០២៦

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្តែកលើយុទ្ធសាស្ត្ររួម ដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់

២. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី ខេត្ត

៣. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ

៤. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ នៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជាក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត

៥. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេស ការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ

៦. ធ្វើវិសោធនកម្មច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដើម្បីឆ្លើយតបទៅនឹងការវិវត្តន៍ថ្មីៗនៃអំពើជួញដូរមនុស្សគ្រប់ទម្រង់

៧. បន្តដោះស្រាយឱកាសការងារ មុខរបរ និងការបង្កើតកម្មវិធីបង្កើនប្រាក់ចំណូល តាមវិធីសាស្ត្រជំនាញ និងគោលនយោបាយ នៃវិស័យពាក់ព័ន្ធ ដល់ប្រជាពលរដ្ឋ ជាពិសេស ក្នុងចំណោមជនទេសន្តរប្រវេសន៍វិលត្រឡប់ និងគ្រួសារជនក្រៀសសឹក

៨. រៀបចកិច្ចប្រជុំវាយតម្លៃពាក់កណ្តាលអាណត្តិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤-២០២៨

៩. រៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលស្តីពី ទេសន្តរប្រវេសន៍ ជាមួយអ្នកសារព័ត៌មាន និងអ្នកផលិតមាតិកាផ្សេងៗ ក៏ដូចជាមន្ត្រីព័ត៌មាន ដើម្បីជំរុញការផ្សព្វផ្សាយបន្តឱ្យមានប្រសិទ្ធភាព៕

ថ្ងៃ.........................ខែ............ ឆ្នាំ................ស័ក ព.ស ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី...៣០.. ខែ...មករា...ឆ្នាំ២០២៦

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គជបជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារ គជបជ

-អគ្គលេខាធិការដ្ឋាន គជបជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ

## ការងារសម្របសម្រួល

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖
  - ពិធីអបអរសាទរ ខួបលើកទី១១៥ ទិវាអន្តរជាតិ ៨មីនា ឆ្នាំ២០២៦ ក្រោមប្រធានបទ «សន្តិភាពនិងសន្តិសុខ សម្រាប់ស្ត្រី និងគ្រួសារ» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង លោកជំទាវ **កែ សួនសុភី** ប្រធានកិត្តិយសក្រុមការងារយេនឌ័រ ក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ
  - កិច្ចប្រជុំប្រចាំសប្តាហ៍ តាមដានវឌ្ឍនភាពការងារបង្ក្រាបបទល្មើសឆបោក តាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams) ក្រោមសហអធិបតីដ៏ខ្ពង់ខ្ពស់ ឯកឧត្តមសន្តិបណ្ឌិត **នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំសម្តេចក្រឡាហោម ស ខេង ទីស្តីការក្រសួងមហាផ្ទៃ
  - កម្មវិធីសម្ពោធ រូបគំនូរសិល្បៈដើម្បីសន្តិភាព នៅបរិវេណខាងមុខវត្តបទុមវតី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ហ៊ុន ម៉ានី** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
  - សិក្ខាសាលាថ្នាក់ជាតិ ផ្សព្វផ្សាយអនុក្រឹត្យ ស្តីពីការគ្រប់គ្រងទារកដ្ឋាន ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច នៅសណ្ឋាគារ ណូវ៉ូថែល រាជធានីភ្នំពេញ
  - កិច្ចប្រជុំតាមប្រព័ន្ធអនឡាញ របស់ប្រទេសជ័យលាភី នៅអាស៊ីប៉ាស៊ីភិច ដើម្បីពិភាក្សាក្នុងការរៀបចំរបាយការណ៍ និងការប្តេជ្ញាចិត្តរួម នៃប្រទេសជ័យលាភីទាំង១០ត្រៀមចូលរួម ក្នុងកិច្ចប្រជុំត្រួតពិនិត្យ ការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយនិងស្របច្បាប់ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២៦ខាងមុខ នៅទីក្រុងញូយ៉ក កិច្ចប្រជុំតាមប្រព័ន្ធអនឡាញនេះដឹកនាំដោយ រដ្ឋមន្ត្រី ក្រសួងទេសន្តរប្រវេសន៍ នៃសាធារណរដ្ឋហ្វីជី
  - បានចូលរួមជាអធិបតី ក្នុងពិធីអបអរសាទរទិវាជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ក្រោមប្រធានបទ «រួមគ្នាដើម្បីកម្ពុជា គ្មានអំពើជួញដូរមនុស្ស និងគ្មានអំពើឆបោកតាមអនឡាញ» នៅខេត្តកំពង់ឆ្នាំង
  - ដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផល នៃការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព ប្រចាំឆ្នាំ២០២៥ និងលើកទិសដៅការងារ ឆ្នាំ២០២៦ របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង នៅសាលាខេត្តកំពង់ឆ្នាំង
  - ជាគណៈអធិបតីក្នុងពិធីបើកយុទ្ធនាការផ្សព្វផ្សាយ ស្តីពីការបង្ការ និងទប់ស្កាត់ ការប្រើប្រាស់ពលកម្មកុមារ និងលើកកម្ពស់លក្ខខណ្ឌការងារ សម្រាប់កម្មករនិយោជិតវ័យក្មេងនៅតាម សហគ្រាស ក្រោមអធិបតីភាព លោកជំទាវ **សុវណ្ណ វណ្ណារតន៍** រដ្ឋលេខាធិការប្រចាំការ នៅខេត្តក្រចេះ
  - បានចូលរួមជាអធិបតី ក្នុងពិធីអបអរសាទរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ក្រោមប្រធានបទ «រួមគ្នាដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស និងគ្មានអំពើឆបោកតាមអនឡាញ» នៅខេត្តសៀមរាប
  - ជាអធិបតីក្នុងសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការវាយតម្លៃដោយស្ម័គ្រចិត្តថ្នាក់ជាតិ លើការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅសាលប្រជុំសណ្ឋាគារសោម៉ាទេវី ខេត្តសៀមរាប
  - ជាអធិបតីក្នុងវគ្គបណ្តុះបណ្តាល កិច្ចការពារកុមារក្នុងបរិបទទេសន្តរប្រវេសន៍ និងផ្សព្វផ្សាយសេចក្តីណែនាំ ស្តីពីការប្រមូលទិន្នន័យពលរដ្ឋធ្វើចំណាកស្រុក និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ ដល់មន្ត្រីគ.រ.ប.ជ/គ.ខ.ប.ជ ២លើក ដែលរៀបចំឡើងដោយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដោយមានកិច្ចសហការពី រដ្ឋបាលខេត្តស្ទឹងត្រែង និងរដ្ឋបាលខេត្តកំពង់ចាម និងគាំទ្រដោយអង្គការ UNICEF ក្រោមគម្រោងជំនួយរបស់ សហគមន៍អឺរ៉ុប (នៅខេត្តស្ទឹងត្រែង និងខេត្តកំពង់ចាម)
  - ដឹកនាំក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ និងក្រុមការងារអង្គការ ដៃកម្ពុជា ចុះសួរសុខទុក្ខ និងនាំយកអំណោយជាសម្ភារៈប្រើប្រាស់ គ្រឿងឧបភោគបរិភោគ ជាកញ្ចប់ជំនួយសង្គ្រោះបន្ទាន់ ដែលសហការរៀបចំឧបត្ថមគាំទ្រដោយ គ.ជ.ប.ជ ក្រសួងសង្គមកិច្ច និងអង្គការដៃកម្ពុជា (ARM) ដើម្បីចែកជូនដល់ជនភៀសសឹកចំនួន១៥៦គ្រួសារ កំពុងស្នាក់នៅបណ្តោះអាសន្ន មណ្ឌលសុវត្ថិភាពភៀសសឹក មកពី៤មណ្ឌលក្រុងរៀមរាប។

- លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖
  - ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងផ្សព្វផ្សាយផែនការយុទ្ធនាការប្រយុទ្ធប្រឆាំង គ្រឿងញៀនខុសច្បាប់ លើកទី១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជណាចក្រកម្ពុជា នៅសណ្ឋាគាររ៉េស៊ីដង់ សុខាភ្នំពេញ
  - ក្នុងពិធីប្រគល់សញ្ញាបត្រ និងវិញ្ញាបនបត្រ ជូនដល់និស្សិត សិស្ស និងសិក្ខាកាមនគរបាលជ័យលាភី ក្រោមអធិបតីភាព ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅបណ្ឌិត្យសភានគរបាលកម្ពុជា
  - ពិធីអបអរសាទរ ខួបលើកទី១១៥ ទិវាអន្តរជាតិ ៨មីនា ឆ្នាំ២០២៦ ក្រោមប្រធានបទ «សន្តិភាពនិងសន្តិសុខ សម្រាប់ស្ត្រី និងគ្រួសារ» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង លោកជំទាវ **កែ សួនសុភី** ប្រធានកិត្តិយសក្រុមការងារយេនឌ័រ ក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ
  - សិក្ខាសាលាថ្នាក់ជាតិ ផ្សព្វផ្សាយអនុក្រឹត្យ ស្តីពីការគ្រប់គ្រងទារកដ្ឋាន ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច នៅសណ្ឋាគារ ណូវ៉ូថែល រាជធានីភ្នំពេញ
  - រៀបចំ និងអបអរទិវានារីអន្តរជាតិ ខួបលើកទី១១៥ របស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅបន្ទប់ប្រជុំ គ.ជ.ប.ជ
  - ពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០២៥ និងលើកទិសដៅការងារ ឆ្នាំ២០២៦ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងផ្សព្វផ្សាយផែនការយុទ្ធនាការប្រយុទ្ធប្រឆាំង គ្រឿងញៀន ខុសច្បាប់ លើកទី១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមសន្តិបណ្ឌិត **នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី នៅសណ្ឋាគាររ៉េស៊ីដង់ សុខាភ្នំពេញ
  - ក្នុងពិធីអបអរសាទរ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្ស ១២ធ្នូ ២០២៥ លើកទី១៩ ក្រោមប្រធានបទ "រួមគ្នាដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស និងគ្មានអំពើឆបោកតាមអនឡាញ" ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅខេត្តកំពង់ឆ្នាំង១លើក ខេត្តសៀមរាប១លើក
  - ជាអធិបតី ក្នុងកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានតាមអនឡាញ នៅសាលារៀនអន្តរទ្វីបអាមេរិកកាំង (AIS) សាខាជ្រោយចង្វារ រាជធានីភ្នំពេញ១លើក ខេត្តកំពង់ចាម១លើក
  - សិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការវាយតម្លៃដោយស្ម័គ្រចិត្តថ្នាក់ជាតិ លើការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅសាលប្រជុំសណ្ឋាគារសោម៉ាទេវី ខេត្តសៀមរាប
  - ជាគណៈអធិបតី ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផល នៃការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព ប្រចាំឆ្នាំ ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង នៅសាលាខេត្តកំពង់ឆ្នាំង
  - ជាគណៈអធិបតី ក្នុងពិធីបើវគ្គបណ្តុះបណ្តាលកិច្ចការពារកុមារ ក្នុងបរិបទទេសន្តរប្រវេសន៍និងផ្សព្វផ្សាយ សេចក្តីណែនាំ ស្តីពីការប្រមូលទិន្នន័យ ពលរដ្ឋធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ ដល់មន្ត្រី គ.រ.ប.ជ/គ.ខ.ប.ជ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅខេត្តស្ទឹងត្រែង
  - ដឹកនាំប្រតិភូអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងអង្គការមេត្រី អន្តរជាតិ (AIM) អញ្ជើញចុះពិនិត្យស្ថានភាព ទីតាំង និងប្រគល់អំណោយជាថវិកា ជូនតំណាងសាលា ដើម្បីសាងសង់ទីសុវត្ថិភាព សម្រាប់លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស នៅសាលាបឋមសិក្សារ ហ៊ុន សែន ភ្នំព្រឹក ស្ថិតក្នុងភូមិបេងស្អាត ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។
- **លេខាធិការដ្ឋាន គ.ជ.ប.ជ**
  - លិខិតរបស់ គ,ជ,ប,ជ៖ លិខិតចេញ (៤៧ច្បាប់) លិខិតចូល (១៩ច្បាប់)
  - លិខិតរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ(១៦ច្បាប់) លិខិតចូល (១៨ច្បាប់)
- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**
  - បានប្រជុំកម្រិតបច្ចេកទេស រៀបចំមេរៀនគោលសម្រាប់វគ្គបណ្តុះបណ្តាល សៀវភៅស្តីពីក្របខ័ណ្ឌតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ និងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០២៤-២០២៨ ក្រោមអធិបតីភាព លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ

- បានរៀបចំកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង ស្តីពី«ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និង ចំណាកស្រុកដោយគ្មានសុវត្ថិភាព និងជម្រើសមុខរបរ និងការងារ» ១៦លើក មានអ្នកចូលរួមចំនួន ២,៥៥០នាក់
- បានចូលរួមជាមួយក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារក្នុងបរិបទទេសន្តរប្រវេសន៍ និងផ្សព្វផ្សាយសេចក្តីណែនាំ ស្តីពីការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ ដល់មន្ត្រី គ.រ.ប.ជ/គ.ខ.ប.ជ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ សហការគាំទ្រអង្គការ UNICEF ក្រោមគម្រោងជំនួយរបស់សហគមន៍អឺរ៉ុប ខេត្តស្ទឹងត្រែង១លើក និងខេត្តកំពង់ចាម១លើក។

- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**
  - បានចូលរួមកិច្ចប្រជុំឆ្លងសេចក្តីព្រាងច្បាប់ ស្តីពីអន្តោប្រវេសន៍ថ្មី ក្រោមអធិបតីភាព ឯកឧត្តម អភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ
  - បានចូលរួមសិក្ខាសាលា ពិគ្រោះយោបលភាពជាដៃគូ ជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តគម្រោងកាន់តែរឹងមាំ របស់អង្គការ ADRA ដែលផ្តោតសំខាន់ទៅលើស្ត្រី និងកុមារ ក្នុងការធ្វើឱ្យប្រសើរឡើងនូវសុខភាព ផ្លូវចិត្តផ្លូវភេទ និងកាការបន្តពូជ ក្រោមអធិបតីភាព លោកជំទាវ **ប៉ាង រ៉ាវី** អភិបាលរង នៃគណៈអភិបាលខេត្តព្រះវិហារ ចំនួន៧១នាក់ ស្ត្រី២៩នាក់ នៅខេត្តព្រះវិហារ
  - បានចូលរួមកិច្ចប្រជុំពិនិត្យនិងបូកសរុបលទ្ធផលការងារ នៃការអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការកាត់បន្ថយពលកម្មកុមារ និងបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មកុមារ ២០១៦-២០២៥ ប្រចាំឆ្នាំ២០២៥ ក្រោមអធិបតីភាព ឯកឧត្តម **វ៉េង ហៀង** អនុរដ្ឋលេខាធិការ ក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ នៅទីស្តីការក្រសួងការងារ
  - បានចូលរួមកិច្ចប្រជុំ ស្តីពីការកសាងស្ថាប័ន កំណែទម្រង់រដ្ឋបាល កំណែទម្រង់ច្បាប់ តុលាការអភិបាលកិច្ច និងសិទ្ធិមនុស្ស ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ អ្នកចូលរួមចំនួន១២នាក់ ស្រី២នាក់ នៅសាលប្រជុំ ទីស្តីការក្រសួងមហាផ្ទៃ
  - បានចូលរួមកិច្ចប្រជុំ(ZOOM) គណៈកម្មការសទ្ទានុក្រមបច្ចេកសព្ទ ក្នុងវិស័យសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **ឯក មនោសែន** ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អ្នកចូលរួមចំនួន៦៤នាក់ (ចូលរួមផ្ទាល់មាន២៤នាក់ តាមអនឡាញ ៤០នាក់) នៅសាលាបណ្ឌិត្យសភានគរបាលកម្ពុជា និងសាលប្រជុំ គ.ជ.ប.ជ
  - បានចូលរួមកិច្ចប្រជុំ គណៈកម្មាធិការចំរុះកម្ពុជា សហភាពអ៊ឺរ៉ុប លើកទី១៣អនុក្រម ស្តីពីការកសាងស្ថាប័ន កំណែទម្រង់រដ្ឋបាល កំណែទម្រង់ច្បាប់ តុលាការអភិបាលកិច្ច និងសិទ្ធិមនុស្ស ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងលោកស្រី PAOLO PAMPALINI ប្រធានគណៈប្រតិភូសហគមន៍អឺរ៉ុប សរុបចំនួន៦៣នាក់ ស្រី១៣នាក់ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ

- **ក្រុមជំនួយកិច្ចការយុត្តិធម៌**
  - បានចូលរួម កម្មវិធីបើកយុទ្ធនាការផ្សព្វផ្សាយថ្នាក់ជាតិ ស្តីពីការលើកកម្ពស់ការយល់ដឹង «អំពើជួញដូរមនុស្ស ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងមជ្ឈមណ្ឌលឆបោក» ក្រោមអធិបតីភាព ឯកឧត្តម **ម៉ុក ច័ន្ទសុជា** រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី និងជាអនុប្រធានលេខាធិការដ្ឋាន គណៈកម្មការចំពោះកិច្ច ប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា អ្នកចូលរួមសរុបចំនួន១២១នាក់ ស្រី៦២នាក់ នៅសាលប្រជុំ សណ្ឋាគារ SUN&MOON
  - បានចូលរួម ប្រជុំត្រួតពិនិត្យសៀវភៅបច្ចេកសព្ទក្នុងវិស័យសន្តិសុខ នៃក្រសួងមហាផ្ទៃ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព ឯកឧត្តមនាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ **ឯក មនោសែន** ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា
  - បានចូលរួមកិច្ចប្រជុំបែងចែកតួនាទីភារកិច្ច ត្រៀមរៀបចំកម្មវិធី សំណេះសំណាលជាមួយនិវត្តន៍ជនជាស្ត្រី ក្រសួងមហាផ្ទៃ ដឹកនាំដោយ លោកជំទាវ **ជូ ប៊ុនអេង** ប្រធានប្រតិបត្តិគណៈកម្មការសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ ក្រសួងមហាផ្ទៃ នៅសាលប្រជុំខេត្តសៀមរាប ទីស្តីការក្រសួងមហាផ្ទៃ។

- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិនិងអន្តរជាតិ**
  - បានអមដំណើរ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចូលរួមកម្មវិធីសម្ពោធរូបគំនូរសិល្បៈ ដើម្បីសន្តិភាព ក្រោមអធិបតីភាព ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ហ៊ុន ម៉ានី** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ នៅបរិវេនខាងមុខវត្តបទុមវតី

- បានដឹកនាំកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាពការងារ ត្រៀមរៀបចំពិធីផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ និងលើកទិសដៅការងារ ឆ្នាំ២០២៦
- បានចូលរួមកម្មវិធី ផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានតាមអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប. នៅសាលារៀនអន្តរទ្វីបអាមេរិកកាំង (AIS) សាខាជ្រោយចង្វារ រាជធានីភ្នំពេញ
- បានអមដំណើរ លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ ចុះពិនិត្យស្ថានភាពទីតាំង និងប្រគល់អំណោយជាថវិកា ជូនតំណាងសាលា ដើម្បីសាងសង់ទីសុវត្ថិភាព សម្រាប់លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស នៅសាលាបឋមសិក្សា ហ៊ុន សែន ភ្នំព្រឹក ស្ថិតក្នុងភូមិបេងស្អាត ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង
- បានចូលរួមពិធីអបអរទិវា ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ក្រោមប្រធានបទ"រួមគ្នាដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស និងអំពើឆបោកតាមអនឡាញ" ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅខេត្តសៀមរាប
- បានចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផល នៃការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព ប្រចាំឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង នៅសាលាខេត្តកំពង់ឆ្នាំង
- បានអមដំណើរ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងជាប្រធានក្រុមការងារត្រួតពិនិត្យ និងជំរុញការអនុវត្ត គោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" ក្រុងកំពង់ឆ្នាំង នៅសាលប្រជុំក្រុងកំពង់ឆ្នាំង
- បានចូលរួមកិច្ចប្រជុំប្រចាំត្រីមាសទី១ ឆ្នាំ២០២៦ របស់ក្រុមការងារ ស.ស.យ.ក ក្នុងវិស័យមហាផ្ទៃ ដឹកនាំដោយ ឯកឧត្តម **ខៀវ ភារិទ្ធ** ប្រធានក្រុមការងារ ស.ស.យ.ក វិស័យមហាផ្ទៃ។ កិច្ចប្រជុំនេះមានការចូលរួមពី ឯកឧត្តម លោកជំទាវ អនុប្រធានក្រុមការងារ ស.ស.យ.ក. វិស័យមហាផ្ទៃ ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារ ស.ស.យ.ក. តាមបណ្តាអគ្គនាយកដ្ឋាន អង្គភាព ព្រមទាំងក្រុមការងារលេខាធិការដ្ឋាន ស.ស.យ.ក. វិស័យមហាផ្ទៃ។

- **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍:**
  - បានរៀបចំឯកសារសម្រាប់បើកវគ្គបណ្តុះបណ្តាលស្តីពី កិច្ចការពារកុមារក្នុងបរិបទទេសន្តរប្រវេសន៍ និងផ្សព្វផ្សាយសេចក្តីណែនាំ ស្តីពីការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ នៅខេត្តស្ទឹងត្រែង និងខេត្តកំពង់ចាម
  - បានសហការជាមួយក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ រៀបចំវគ្គបណ្តុះបណ្តាល កិច្ចការពារកុមារក្នុងបរិបទទេសន្តរប្រវេសន៍ និងផ្សព្វផ្សាយសេចក្តីណែនាំស្តីពី ការប្រមូលទិន្នន័យពលរដ្ឋ ធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ ដល់មន្ត្រី គ.រ.ប.ជ/គ.ខ.ប.ជ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តក្រចេះ និងខេត្តព្រះវិហារ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំខេត្តស្ទឹងត្រែង
  - បានសហការជាមួយក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ រៀបចំវគ្គបណ្តុះបណ្តាល កិច្ចការពារកុមារក្នុងបរិបទទេសន្តរប្រវេសន៍ និងផ្សព្វផ្សាយសេចក្តីណែនាំស្តីពី ការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ ដល់មន្ត្រី គ.រ.ប.ជ/គ.ខ.ប.ជ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តកំពង់ធំ ខេត្តព្រៃវែង និងខេត្តស្វាយរៀង ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំខេត្តកំពង់ចាម។

- **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**
  - បានចូលរួមកិច្ចប្រជុំអនុក្រុម ស្តីពីការកសាងស្ថាប័ន កំណែទម្រង់រដ្ឋបាល កំណែទម្រង់ច្បាប់ និងតុលាការ អភិបាលកិច្ច និងសិទ្ធិមនុស្ស ក្រោមអធិបតីភាព ឯកឧត្តមនាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារ នៅបន្ទប់ប្រជុំទីស្តីការក្រសួងមហាផ្ទៃ
  - បានក្នុងពិធីអបអរសាទរ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្ស ១២ធ្នូ ២០២៥ លើកទី១៩ ក្រោមប្រធានបទ "រួមគ្នាដើម្បីកម្ពុជាគ្មានអំពើជួញដូរមនុស្ស និងគ្មានអំពើឆបោកតាមអនឡាញ" ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅខេត្តកំពង់ឆ្នាំង
  - បានចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផល នៃការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព ប្រចាំឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង នៅសាលាខេត្តកំពង់ឆ្នាំង

- បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការចម្រុះ កម្ពុជា-សហភាពអឺរ៉ុបលើកទី១៣ អនុក្រុមស្តីពី ការកសាងស្ថាប័ន កំណែទម្រង់រដ្ឋបាល កំណែទម្រង់ច្បាប់និងតុលាការ អភិបាលកិច្ចនិងសិទ្ធិមនុស្ស
- បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការចម្រុះ កម្ពុជា-សហភាពអឺរ៉ុបលើកទី១៣ កិច្ចប្រជុំពេញអង្គ
- បានចាប់តាំងពីថ្នាក់ដឹកនាំ គ.ជ.ប.ជ ចូលរួមកម្មវិធីបើកយុទ្ធនាការផ្សព្វផ្សាយថ្នាក់ជាតិ ស្តីពីការលើកកម្ពស់ការយល់ដឹង "អំពើជួញដូរមនុស្សដើម្បីបង្ខំឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងមជ្ឈមណ្ឌលឆបោក" ធ្លាក់ក្នុងអន្ទាក់ឧក្រិដ្ឋកម្មឆបោក ក្រោមអធិបតីភាពឯកឧត្តម **មុខ ច័ន្ទសុជា** រដ្ឋលេខាធិការស្តីទីការគណៈរដ្ឋមន្ត្រី និងជាអនុប្រធានលេខាធិការដ្ឋាន គណៈកម្មការចំពោះកិច្ចប្រយុទ្ធប្រឆាំងការចូលបោកតាមប្រព័ន្ធបច្ចេកវិទ្យា(គ.ប.ឆ.ប) នៅសណ្ឋាគារSUN&MOON មានអ្នកចូលរួមពី តំណាងក្រសួងស្ថាប័នពាក់ព័ន្ធ តំណាងស្ថានទូត អង្គការសង្គមស៊ីវិល វិស័យឯកជនដៃគូអភិវឌ្ឍន៍ជាតិ-អន្តរជាតិ និងតំណាងយុវជន សរុបចំនួន១២១នាក់ ស្រី៦២នាក់។

- **ខេត្តកណ្តាល**
  - បានចូលរួមប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២៥ និងលើកទិសដៅការងារបន្តឆ្នាំ២០២៦ របស់គ.ជ.ប.ជ **ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ
  - បានចូលរួមបើកវគ្គបំប៉ន ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការឆបោកតាមប្រព័ន្ធអនឡាញ និងទប់ស្កាត់ការប្រើអំពើហិង្សាក្នុងគ្រួសារ តាមប៉ុស្តិ៍នគរបាលនៃអធិការដ្ឋាន និងប៉ុស្តិ៍នគរបាលរដ្ឋបាល។
- **ខេត្តបាត់ដំបង**
  - បានចូលរួមប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២៥ និងលើកទិសដៅការងារបន្តឆ្នាំ២០២៦ របស់គ.ជ.ប.ជ **ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ
  - បានចូលរួមជាអធិបតីក្នុងពិធីបើក និងជាវាគ្មិនក្នុងវេទិកាថ្នាក់ខេត្ត ស្តីពី "ការជួយគាំទ្រដល់កុមារមានពិការភាព" នៅសាលប្រជុំមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង
  - បានចូលរួមជាអធិបតីក្នុងពិធីបើកសិក្ខាសាលា ស្តីពីការអនុវត្តផែនការអេចិន្ត្រៃយ៍សម្រាប់កុមារ តាមរយៈការសុំកូនក្នុងប្រទេស នៅសណ្ឋាគារប្រេស៊ីដង់ ក្រុងបាត់ដំបង
  - បានចូលរួមកិច្ចប្រជុំសាមញ្ញលើកទី១៩ ប្រចាំខែកុម្ភៈ ឆ្នាំ២០២៦ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត អាណត្តិទី៤ នៅសាលប្រជុំ សាលាខេត្តបាត់ដំបង។
  - **ខេត្តព្រៃវែង** បានចូលរួមផ្សព្វផ្សាយសេចក្តីណែនាំស្តីពី ការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ ដល់មន្ត្រី គ.រ.ប.ជ/គ.ខ.ប.ជ ដែលរៀបចំឡើងដោយ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ធ្វើនៅខេត្តកំពង់ចាម។

- **ខេត្តឧត្តរមានជ័យ**
  - បានចូលរួមប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២៥ និងលើកទិសដៅការងារបន្តឆ្នាំ២០២៦ របស់គ.ជ.ប.ជ **ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។
  - បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ ស្តីពី«ការវាយតម្លៃការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍(GCM)» នៅខេត្តសៀមរាប។
- **ខេត្តកោះកុង៖** បានចូលរួមប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២៥ និងលើកទិសដៅការងារបន្ត ឆ្នាំ២០២៦ របស់គ.ជ.ប.ជ **ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។

- **ខេត្តមណ្ឌលគិរី**
  - បានចូលរួមប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២៥ និងលើកទិសដៅការងារបន្តឆ្នាំ២០២៦ របស់គ.ជ.ប.ជ **ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។
  - បានចូលរួមផ្សព្វផ្សាយសេចក្តីណែនាំស្តីពី ការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ដល់មន្ត្រី គ.រ.ប.ជ/គ.ខ.ប.ជ ដែលរៀបចំឡើងដោយ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ធ្វើនៅខេត្តស្ទឹងត្រែង។
- **ខេត្តបន្ទាយមានជ័យ**
  - បានចូលរួមសិក្ខាសាលាចែករំលែកបទពិសោធន៍ លើការអនុវត្តតួនាទី ភារកិច្ច របស់លេខាធិការដ្ឋាន គ.ខ.ប.ជ រវាងខេត្ត (សៀមរាប-កំពង់ចាម-កំពង់ធំ និងបន្ទាយមានជ័យ) ធ្វើនៅខេត្តសៀមរាប។
  - បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី ការវាយតម្លៃការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ (GCM) ធ្វើនៅខេត្តសៀមរាប។
- **ខេត្តកំពង់ធំ**
  - បានចូលរួមកម្មវិធីអបអរសាទរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ លើកទី១៩ ឆ្នាំ២០២៦ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំកោះពេជ្រ
  - បានចូលរួមអបអរសាទរខួបលើកទី១១៥ ទិវាអន្តរជាតិនារី៨មីនា ឆ្នាំ២០២៦ នៅទីស្តីការក្រសួងមហាផ្ទៃ
  - បានចូលរួមសិក្ខាសាលាចែករំលែកបទពិសោធន៍លើការអនុវត្តន៍ តួនាទី ភារកិច្ច របស់លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត នៅខេត្តសៀមរាប
  - បានចូលរួមវគ្គបណ្តុះបណ្តាលអំពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ នៅខេត្តកំពង់ធំ
  - បានចូលជាគ្រូឧទ្ទេសនាមស្តីពី ១.ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ២.និយមន័យយេនឌ័រ ដល់សិក្ខាកាមជាមន្ត្រីនគរបាលថ្មី សរុបចំនួន៧៤នាក់ ស្រីចំនួន០៩នាក់ នៅសាលប្រជុំស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ
  - បានចូលរួមវគ្គបណ្តុះបណ្តាលមន្ត្រីបង្គោលថ្នាក់ស្រុក ស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារកុមារសម្រាប់រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ នៅសាលាខេត្តកំពង់ធំ។